Reçu le 27-11-51

INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

# មិត្តសាលាបាលី

ទស្សនាវដ្ដីផ្សាយពុទ្ធសាសនា និង អក្សរសាស្ត្រខ្មែរ

ចេញរាល់ខែ



ឆ្នាំទី២ មេសា - ឧសភា លេខ ៤-៥

ព.ស. ២៤៩៤ — គ.ស. ១៩៥១

ទស្សនាវដ្ដីអនុមាសផ្សាយព្រះពុទ្ធសាសនានិងអក្សរសាស្ត្រខ្មែរ

បណ្ណាធិការ ឈឹម-ក្រសេម

សំណាក់ការ លេខ ៣៩ អា., វិថីឧកញ៉ាពេជ្រ ក្រុងភ្នំពេញ

## បញ្ជីរឿង


| | | ទំព័រ |
| --- | --- | --- |
| ពរឆ្នាំថោះ | មិត្តសាលាបាលី | ១២១ |
| វិចារណកថា | | ១២៣ |
| បទពិចារណាអំពីចូលឆ្នាំថ្មី | សុភមិត្ត | ១២៧ |
| វិសាខមង្គលសម័យ | ហេង - យ៉ាន់ | ១៣៩ |
| វិសាខបូជាកថា | ប. ស. ធម្មាភាម | ១៤៥ |
| ព្រះពុទ្ធសាសនាគឺអ្វី ? | ភិក្ខុ ប៉ាង - ខាត់ | ១៥៦ |
| អរិយទ្រព្យ ៧ ប្រការ | ព្រះទេពសត្ថា សូរ - ហាយ | ១៧៥ |
| បណ្ឌិត ម៉ាលាល៉ះសេកោះមកប្រទេសកម្ពុជា | មិត្តសាលាបាលី | ១៩០ |
| ថ្ងៃផ្សាយមេត្តា | មិត្តសាលាបាលី | ១៩៥ |


---

ដំឡៃជាវប្រចាំឆ្នាំ ១០០ រៀល

អ្នកអានទាំងឡាយ! សូមអញ្ជើញចុះឈ្មោះជាវ!

និងបបួលញាតិមិត្តជួយជាវ!

ជីវិតទស្សនាវដ្ដីសូមផ្ញើលើលោកអ្នក ។

P.K-20
1951-(4,5)

# ពរឆ្នាំថោះ

ឆ្នាំខាលផុតបាត់ស្ងាត់ឈឹង ជញ្ជឹងពិនិត្យគិតគ្រប់
ពុំបានក្សាន្តពីឧបទ្រព ស្រាប់តែសម្ភពឆ្នាំថ្មី ។
ឆ្នាំថោះផ្ទោះមកដល់ហើយ សមស្បើយល្ហើយចិត្តឥតបី
ទើបមិត្តសាលាបាលី ឃ្លាតខ្លីជូនពរទាំងប្អូន ។

អាយុយឺនយូរសួស្តី វណ្ណៈប្រិមប្រិយនិមនួន
សុខៈឥតប្រែថែជួន ពលៈមាំមួនខ្ជួនប្រាណ ។
សូមគុណរ័តនត្រៃថ្លៃថ្លា ជ្រោមជ្រែងរក្សាអ្នកអាន
រួមពង្សវង្សញាតិសន្តាន មនុស្សសត្វសព្វឋានបានសុខ ។

រស្មីឆ្នាំថ្មីព្រោងព្រុះ ចំរុះផ្ទុះបប់សព្វស្រុក
រស្មីកំចាត់អផ្សុក អុកឡុកបុកបែនឧភ ។
រស្មីផ្សព្វផ្សាយសាមគ្គី គ្រប់ទិសគ្រប់ទីភ្លឺថ្លា
រស្មីចែកចាយមេត្តា ភក្តីស្នេហាទូទៅ ។

ពីពរទាំងប្អូនថ្កើងថ្កាន នឹងបានមូលមិត្រនិត្យនៅ
ដោយសារមេត្តាជ្រាលជ្រៅ កំចាត់ឃោរឃៅចេញឆ្ងាយ ។
ដោយយើងស្មោះសរទទួល សម្រួលទាំងចិត្តទាំងកាយ
បណ្តុះពូជប្អូនសុសសាយ ខ្វល់ខ្វាយថែទាំសព្វផង ។

ប្រាថ្នាអាយុយឺនយូរ គិតគូរគាន់សីលចាំចង
គោរពក្ដីសុខអ្នកផង កុំឲ្យមានហ្មងសព្វកាល ។

ចង់បានសម្បូរវណ្ណៈ សុភៈវិសេសវិសាល
ប្រយ័ត្នទោសៈបណ្ដាល ចិត្តស្រាលក្រញឹងខឹងខ្លាំង ។

កុំជុតភ្លើងឲ្យពេលពល យកមុខទៅផ្លាលតតាំង
ប្រឹងទប់បង្អន់កំឡាំង ក្រោធខ្មាំងអស់ពីសន្ដាន ។

ប៉ុនប៉ងសុខៈថេរថិត ខាត់ចិត្តឲ្យល្អបំណាន
ផ្លូវផង់អស់បាបផ្អាបប្រាណ កិលេសប៉ុន្មានច្រានបង់ ។

លោភោទោសោមោហោ នេះមេបាបបោដ៏កង់
សត្រូវហាវហានផ្ចាញអង្គ គួរផ្ចង់កំចាត់ឲ្យក្ស័យ ។

ត្រូវការពលៈមាំមួន ត្រូវខំថែខ្លួនសព្វថ្ងៃ
ឲ្យអស់រោគាចង្រៃ ប្រល័យឲ្យបាត់ខ្ចាត់ខ្ចាយ ។

ទាំងត្រូវធ្វើការហាត់ប្រាណ ឲ្យបានស្វាហាប់ក្នុងកាយ
ជាហេតុឲ្យចិត្តស្រស់ស្រាយ ឧបាយឲ្យកើតបញ្ញា ។

បើយើងសាទរពរបួន ត្រូវប្រឹងសាងខ្លួនអាត្មា
កុំដេកចាំផ្សងពស្នា ទើបចួបពរថ្វាឆ្នាំថ្មី ។

មិត្តសាលាបាលី

## វិចារណាកថា

ច្បាប់ដែលយើងប្រារព្ធចាប់រួម ២ លេខជាមួយក្បាល ដើម្បីឲ្យទស្សនាវដ្ដីរបស់យើង ដែលយឺតយូរព្រោះឧបសគ្គផ្សេងៗ បានចេញទាន់ពេលវេលា និងទាន់ចិត្តអ្នកអានទាំងឡាយ ប្រមូលលើលេខទី ៤ ដ៏ជាលេខសំរាប់ឆ្នាំថ្មី និងលេខទី ៥ ដ៏ជាលេខសំរាប់វិសាខបូជា ។ ការគួបលេខ ៤ និងលេខ ៥ រួមបូលគ្នានេះ ពុំមែនធ្វើឡើងដោយឯកឯងទេ ពុំមែនព្រោះឱកាសហុចមកឲ្យទេ គឺដោយបំណងដ៏ជាក់ស្ដែងរបស់យើងចង់ឲ្យច្បាប់នេះប្រកបដោយន័យជ្រាលជ្រៅ ដែលហូរចេញចាកទិវាពិសេសទាំង ២ នៃឆ្នាំ ។ ច្បាប់នេះនឹងជាប្រភពនៃសេចក្ដីសុខសេចក្ដីចំរើនក្នុងជីវភាពនិងសេចក្ដីសង្ឃឹមទុកចិត្តក្នុងអនាគតកាល ។

ដោយពិត យើងនៅចំពោះអរុណនៃឆ្នាំថ្មី ឆ្នាំដែលយើងពឹងផ្អែកនូវសេចក្ដីសង្ឃឹមរបស់យើង នៅចំពោះអរុណនៃសករាជថ្មី សក-រាជដែលនាំនូវពន្លឺរស្មីមកឲ្យយើង ដែលនាំនូវយានមកឲ្យយើង ដឹកនាំយើងទៅកាន់សេចក្ដីសំរេចព្រមនូវសង្ឃឹមរបស់យើង ទៅកាន់សេចក្ដីរុងរោចន៍ ទៅកាន់ទីរំលត់ទុក្ខ ។ អនាគតដ៏រុងរឿងបែបនេះ គួរញុំាងចិត្តយើងឲ្យរីករាយ ឲ្យជ្រះថ្លាក្រៃលែង កាលយើងដឹងជាក់ច្បាស់នូវន័យដ៏គម្ភីរភាពបែបនេះហើយ អនាគតនោះមុខជានឹងមិនបញ្ឆោតយើងទេ តែយើងកុំគប្បីភ្លេចថាយើងជាអ្នកកសាងស្ថានសួគ៌សំរាប់ខ្លួនយើង ឥតមាននរណាមួយអាចជួយយើងបានក្នុងការកសាងខ្លួនយើងទេ ។

សព្វថ្ងៃនេះ យើងត្រូវការសេចក្ដីត្រជាក់កាយត្រជាក់ចិត្ត ត្រូវការសេចក្ដីស្ងប់ចំពោះខ្លួនយើង រវាងខ្លួនយើងនឹងជនដទៃ ៗ តាមដែលរលឹកចាំបាន ឆ្នាំដែលកន្លងទៅនោះពុំបាននាំនូវសេចក្ដីស្ងប់ដ៏ក្សេមមកឲ្យយើងទេ យើងសង្កេតឃើញថា លោកនេះកំពុងឆេះដោយភ្លើងសង្គ្រាម ជាតិមួយយកឈ្នះយកចាញ់នឹងជាតិមួយទៀត រវាងជាតិផងគ្នាក៏មានការទាស់ទែងខ្វែងគំនិតគ្នា ឈ្លោះប្រកែកគ្នា ចងពៀរពៀបាទគ្នាដែរ សូម្បីរួមត្រកូលគ្នា ក៏កើតកលហៈដែរ បងទាស់នឹងប្អូន មានឹងក្មួយ ប្ដីនឹងប្រពន្ធជាដើម គ្មានសេចក្ដីស្ងប់ក្នុងគ្រួសារ ក្នុងវង្សត្រកូល ក្នុងសង្គម ក្នុងជាតិនីមួយ នឹងរវាងជាតិ, មិនតែប៉ុណ្ណោះ ចំពោះខ្លួនរបស់ឯងតែម្នាក់ឯងក៏ប្រាសចាកសេចក្ដីស្ងប់ទៀត ៗ

រស្មីដែលពិសាខបុណ្ណមីផ្សាយគ្របដណ្ដប់មកលើយើង ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់បានធ្វើឲ្យបែងច្បាស់ដល់សត្វលោកទាំងឡាយ នឹងជួយបំភ្លឺផ្លូវយើងទៅកាន់សេចក្ដីស្ងប់នោះ ៗ ព្រះដ៏មានព្រះភាគទ្រង់សម្ដែងប្រាប់ថា "ទីណាប្រាសចាកសេចក្ដីស្ងប់ ទីនោះជាទុក្ខ" ព្រោះហេតុនោះទើបព្រះអង្គប្រៀនប្រដៅឲ្យស្វែងរកសេចក្ដីស្ងប់ចំពោះជនដទៃ សេចក្ដីស្ងប់ចំពោះខ្លួន ស្ងប់កាយស្ងប់ចិត្ត រហូតដល់សេចក្ដីស្ងប់ដ៏ឧត្ដម សេចក្ដីស្ងប់មិនប្រែប្រួលគឺព្រះនិព្វាន ៗ

យើងពុំបាននៅដាច់តែឯងដោយមិនចាំបាច់ប្រស្រ័យទាក់ទងជាមួយអ្នកដទៃទេ យើងតែងតែរាប់រកគេឯងដើម្បីជីវិតជានិច្ច ដោយហេតុនោះអំពើពុំគប្បីរបស់យើងទាំងប៉ុន្មាន រមែងប៉ះពាល់ដល់អ្នកឯទៀតជាធម្មតាជាហេតុឲ្យខូចនូវសេចក្ដីស្ងប់ ដើម្បីស្ងួនរក្សាសេចក្ដីស្ងប់នោះ យើងត្រូវតែស្ងួននូវកាយនឹងវាចារបស់យើងឲ្យសមរម្យដល់អ្នកជិតខាង ប្រព្រឹត្តតែអំពើណាដែលមិនទត្តិចជីវិតនឹងសេចក្ដីសុខនៃអ្នកផង គឺការកាន់សីល ៥ នោះឯង ។ សីលនេះនឹងបរិបូណ៌ហ្មត់ចត់ទៅបាន លុះត្រាតែយើងតាំងចិត្តរាប់អានដោយស្មោះសរចំពោះអ្នករួមលំនៅរួមភពជាមួយគ្នា ផ្សាយមេត្តាចិត្តទូទៅដោយឥតរើសមុខ ដោយយល់ច្បាស់ប្រាកដ ថាយើងស្រឡាញ់អ្វីស្អប់អ្វី គេក៏ស្រឡាញ់នោះស្អប់នោះដែរ ។

មិនគ្រាន់តែប្រាថ្នានឹងគោរពសេចក្ដីសុខ សេចក្ដីចំរើនរបស់ជនដទៃប៉ុណ្ណោះទេ អ្នកចង់បានសេចក្ដីស្ងប់មានករណីយកិច្ចត្រូវឈឺចាប់ចំពោះទុក្ខនៃជនទាំងនោះផង ដោយជួយឈឺឆ្អាលជួយរំលែកទុក្ខ ដ៏ជាគោលការណ៍នៃការឲ្យទាន ។

ស្ងប់ខាងក្រៅផ្ទះសំរេចបានហើយ . គួររក្សាសេចក្ដីស្ងប់ក្នុងផ្ទះផងទៀត មានការស្ងប់រវាងប្ដីប្រពន្ធជាដើម ដោយការយល់ចិត្តយល់ថ្លើមគ្នាទៅវិញទៅមក ដោយសេចក្ដីសន្ដោស ដោយពេញចិត្តបំពេញសុខមិនគិតតែពីទាមទារតែម្យ៉ាង សេចក្ដីស្ងប់ខាងក្នុងនេះ ជាសេចក្ដីស្ងប់

ដែលត្រូវតែរក្សាឲ្យបាន ព្រោះថា បើគ្នាតែពីរនាក់ប៉ុណ្ណោះរកស្ងប់ពុំបានទៅហើយ តើចង់ឲ្យស្ងប់នឹងអ្នកក្រៅដូចម្តេចកើត ។

ឯសេចក្តីស្ងប់នេះនឹងចែករំលែកដល់អ្នកផងទាំងពួងបាន លុះត្រាតែខ្លួនឯងបានសេចក្តីស្ងប់ក្នុងខ្លួនឯងជាមុន ស្ងប់ឥន្ទ្រិយ ស្ងប់ចិត្តចាកអារម្មណ៍ទាំងឡាយ ចាកកិលេសទាំងពួង ដោយការដុសខាត់ចិត្តឲ្យស្អាត នឹងចំរើននូវបញ្ញាឲ្យបានស្វាងច្បាស់ជាប្រទីបដ៏ប្រពៃ ។ កាលបើបានចំរើននូវបញ្ញាភ្លឺថ្លាពេញលេញហើយ ទើបអាចនឹងទ្រោលបំភ្លឺកំចាត់បង់នូវងងឹតងងល់ពោលគឺអវិជ្ជាឲ្យខ្ចាត់ចេញឆ្ងាយចាកសន្តាន ជាហេតុនាំឲ្យបានសេចក្តីស្ងប់យ៉ាងទៀងទាត់ក្នុងសង្គមក្នុងលោក ព្រោះការស្ងប់ក្នុងខ្លួនឯងជាដំបូងនោះ ជាគុណធម៌មួយដ៏ប្រពៃអាចនឹងពង្រីកសេចក្តីស្ងប់យ៉ាងទូលំទូលាយដល់ជនឯទៀតបានដោយពិត ។

សូមរាសីនៃរស្មីឆ្នាំថ្មីនឹងវិសាខបុណ្ណមីស្រោចស្រប់ចិត្តសព្វសត្វទាំងឡាយក្នុងពិភពលោក ឲ្យបានត្រជាក់ចាកភ្លើងលោភៈ ទោសៈ មោហៈ មានអធ្យាស្រ័យទន់លំទោនរកគ្នាដោយស្មោះស្ម័គ្រ ស្វែងរកសេចក្តីសុខសេចក្តីចំរើនដល់គ្នា ជួយដោះទុក្ខគ្នាទៅវិញទៅមក នឹងបានទទួលនូវសន្តិជាលំដាប់ដរាបរៀងទៅ ។

# បទពិចារណាអំពីចូលឆ្នាំថ្មី

ពេលនេះយើងចូលដល់អរុណនៃឆ្នាំថ្មីមួយទៀតហើយ ឯឆ្នាំដែលកន្លងទៅ បានកន្លងទៅមួយអន្លើដោយអាយុជីវិតយើងមួយចំណែកទៅផង អាយុជីវិតដែលប្រកបដោយ យាមសុខ យាមទុក្ខច្របូកច្របល់គ្នា, ឯយាមទុក្ខលុបលើសយាមសុខជាច្រើនភាគ បំណងរបស់យើងនៅពុំទាន់សំរេចនៅឡើយ ហើយយើងបានផ្អែកសេចក្តីសង្ឃឹមរបស់យើងលើឆ្នាំនោះណាស់ ដូចដែលយើងធ្លាប់បានធ្វើមកនៅចំពោះថ្ងៃចូលឆ្នាំថ្មីរៀងរាល់ឆ្នាំ ៗ ឥឡូវនេះ រស្មីនៃឆ្នាំថ្មីរៀងរះឯដើមមេឃម្តងទៀត រស្មីដែលបើកឲ្យយើងសង្ឃឹមជាថ្មី ដែលបញ្ចាញនូវទស្សនភាពដ៏រុងរឿងដែលពេញបរិបូណ៌ដោយសេចក្តីចំរើនដ៏ប្រពៃចំពោះជនទូទៅក្នុងលោក ។

យើងក៏ប្រុងប្រៀបរៀបចំខ្លួនទទឹងជូនពរ សព្ទសាធុការដល់ញាតិមិត្តតាមប្រពៃណីពីបូរាណ ឯពរនេះ យើងបានប្រកាសមកជាច្រើនឆ្នាំតែពុំទាន់ដែលបានសំរេចដូចបំណងនៅឡើយ ជាហេតុនាំឲ្យយើងពិភ័លក្នុងចិត្តថា ចំពោះឆ្នាំថ្មីនេះ តើសេចក្តីសង្ឃឹមរបស់យើងនឹងបានសំរេចផលឬទេ? នឹងមិនដូចឆ្នាំមុន ៗ ទេឬ?

មុននឹងដោះស្រាយនូវប្រស្នានេះ គួរយើងនាំគ្នាពិចារណាអំពីរឿងចូលឆ្នាំថ្មីសិន ដើម្បីឲ្យដឹងថា ឆ្នាំថ្មីនេះនឹងនាំអ្វីមកឲ្យយើងខ្លះហើយយើងអាចនឹងធ្វើអ្វីបាន ។

បើយើងពិចារណាមើលលោកនេះទៅ យើងឃើញថា ពីពេលព្រះអាទិត្យរះដល់ពេលព្រះអាទិត្យអស្ដង្គត យើងសន្មតហៅថាមួយថ្ងៃ ពីពេលព្រះអាទិត្យអស្ដង្គតដល់ពេលព្រះអាទិត្យរះ យើងសន្មតហៅថាមួយយប់ គន់មួយថ្ងៃមួយយប់លោកចាត់ជាមាន ២៤ ម៉ោង កន្លងយប់ថ្ងៃចំនួន ៣០ដង កំណត់ជា១ខែ កន្លងខែ ១២ ដង ជាមួយឆ្នាំ គន់មួយឆ្នាំមានការផ្លាស់ប្ដូររដូវជាច្រើនដង ផ្លាស់ពីរដូវក្ដៅទៅរដូវត្រជាក់ជាដើម ៗ ចំណែកផ្កាយដែលរះនៅវេលាយប់សោតក៏ពុំនៅមួយកន្លែងដែរ ប្ដូរឃើញរះនៅត្រង់នេះ ប្ដូរត្រង់នោះ ប្ដូរម៉ោងថ្មើរនេះ ប្ដូរម៉ោងថ្មើរនោះ ឯយប់វិញក៏មានពេលងងឹតពេលភ្លឺដោយរស្មីព្រះចន្ទ្រ ចំណែកព្រះចន្ទ្រគោចរទៅតាមវេលាចទឹងខ្នើតដែរ ដូច្នេះ លោកនេះតែងប្រែប្រួលតែងវិលទៅជាធម្មតា ពីនេះទៅនោះពីនោះមកកន្លែងដើមវិញសារចុះសារឡើង ទៅតាមគតិថៃតែមួយ គតិប្រព្រឹត្តទៅគង់វង់វិលមួយ ៗ ព្រឹត្តិកម្មខាងលើនេះបញ្ជាក់ឲ្យឃើញថា គង់លោកអ្នកក៏កើតទាំងអស់ ដែលទើបកើតទៅបានដោយអាស្រ័យកំឡាំងបញ្ចេញនូវថាមពលឲ្យប្រតិបត្តិការផ្សេង ៗ ការវិលនោះ គឺ ធាតុភាពនៃថាមពលទាំងនោះ ឃើញថាគ្មានអ្វីនៅដដែលទេ តែងតែប្រព្រឹត្តទៅជានិច្ច គឺប្រកបដោយអនិច្ចលក្ខណៈនោះឯង ៗ

តាមន័យខាងលើនេះ តើយើងចូលឆ្នាំថ្មីមែនឬអ្វី? ការចូលចិត្តថាឆ្នាំថ្មីតោងជាប់ដល់ឆ្នាំចាស់ដែលកន្លងទៅហើយ ដែលនឹងមានថ្មីចាស់បាន លុះតែមានអ្វីមួយជាកណ្ដាលនៅចិតថេរជាសស្សរត្រត្តសំរាប់ទុកជាគ្រឿងប្រៀបធៀប ៗ លោកនេះនៅដដែលឬ? ក្នុងកំឡុងមួយឆ្នាំមានសត្វជាច្រើនដែលចាកឋានទៅ ឬដែលកើតឡើង គេហដ្ឋានជាអនេកដុះផ្កាយបាក់បែកវិនាសបង់ទៅ ឬតុបតែងឡើង ទីដែលធ្លាប់ដេរដាសដោយព្រៃព្រឹក្សា ប្រែក្លាយជាទីវាលខៀវស្រងាត់ដោយដំណាំឃើញថាពុំមែនលោកដដែលទេ ព្រោះធម្មតាំងឡាយកាលមានការកសាងហើយ រមែងតែងវិនាសសូន្យបង់ទៅជាធម្មតា តែលោកនោះក៏វិលទៅតាមតិថិកាលប្រក្រតីរបស់លោក ដែលយើងសន្មតថាឆ្នាំចាស់ឆ្នាំថ្មីនោះ ការវិលចុះវិលឡើងនៃលោកនេះតាមព្រះពុទ្ធសាសនាឈ្មោះថាសង្សារចក្រ ឯសង្សារចក្រនេះ លោកបានពោលថារកដើមកំណើតពុំឃើញទេ ៗ បើនឹងប្រើគ្រឿងឧបមាបញ្ជាក់រឿងនេះ គេអាចពោលដល់អាការផ្លាស់ប្ដូរសភាពនៃទឹកដែលនៅក្នុងទន្លេ ត្រូវកំដៅថ្ងៃខ្លាំងក្លាយជាចំហាយទឹក អណ្ដែតទៅកាន់អាកាសវេហាស៍ ផ្សំគ្នាជាពពក, ពពកត្រូវត្រជាក់ខ្លាំងក៏កកជាទឹកដែលក្លាយជាភ្លៀងបង្អុរចុះមកកាន់ទន្លេវិញ ទឹកនោះលុះត្រូវកំដៅព្រះអាទិត្យនិមិត្តជាចំហាយតទៅទៀតវិលចុះវិលឡើងតែដូច្នេះរៀងរាបទៅ ៗ

ការវិលខាងលើនេះជាហេតុនាំឲ្យយល់ថាមានកាលកន្លងទៅទុកជាអតីត កាលនៅចំពោះមុខជាបច្ចុប្បន្ន កាលមិនទាន់មកដល់ជាអនាគត ឆ្នាំចាស់ជាអតីត ឆ្នាំថ្មីជាបច្ចុប្បន្ន ឆ្នាំខាងមុខជាអនាគត តែកាលទាំងបីនឹងមានបានដោយអាស្រ័យនឹងអ្វីមួយដែលនៅដដែលមិនប្រែប្រួល ព្រោះថាបើប្រែប្រួលទៅស្មើគ្នា មិនអាចនឹងកំណត់កាលវេលាបានឡើយ ។ តែយើងបានឃើញមកហើយថាចក្រវាលទាំងមូលឥតនៅនឹងដដែលទេ តែងតែប្រែប្រួល វិលទៅជាលំដាប់ ដូច្នេះ កាលវេលាពុំអាចកំណត់បានទេ ឯពាក្យថាឆ្នាំចាស់ឆ្នាំថ្មីគ្រាន់តែជាពាក្យសន្មតតាមសេចក្ដីលង់ប៉ុណ្ណោះ ព្រោះលុះដោយសក្កាយទិដ្ឋិ ប្រកាន់ក្នុងខ្លួនប្រាណជាថិតថេរជាប់ណាប់ទៀងទាត់ ។ ព្រោះហេតុនោះ ទើបព្រះបរមគ្រូជាម្ចាស់ទ្រង់ឲ្យឈ្មោះសាវកណាដែលកំចាត់នូវអវិជ្ជាបង់លែងប្រ-ឡូកប្រឡំដោយអតីតនឹងអនាគតថា "អកប្បិយោ" អ្នកឆ្លងផុតការជាប់ជំពាក់ក្នុង កប្ប គឺកាលវេលា ។

ទិដ្ឋិយល់ខុសទាំង ៦២ ប្រការ មានលោកទៀងឬមិនទៀង មានទីបំផុត ឬពុំមានទីបំផុតជាដើម ដែលមានសម្ដែងក្នុងព្រហ្មជាលសូត្រ មកពីប្រកាន់នូវបុព្វន្តនឹងអបរន្តពិចារណាពីរូបខន្ធក្នុងអតីត រូបខន្ធក្នុងអនាគត ។ ក្នុងមិលិន្ទបញ្ហា មានចោទសួររកធម្មជាតិជាមូលហេតុនៃកាលជាអតីត កាលជាបច្ចុប្បន្ន កាលជាអនាគត ព្រះនាគសេនត្ថេរ

បានដោះស្រាយថា: "ឯមូលហេតុនៃកាលទាំង ៣ ប្រការនោះ មិនគឺវត្ថុ ឡើយ គឺអវិជ្ជានោះឯងជាមូលហេតុ ឯអវិជ្ជានោះមិនគឺធម៌ឯណាដទៃទេ គឺបដិច្ចសមុប្បាទធម៌ទាំង ១២ ប្រការ" លោកបានបញ្ជាក់ថែមទៀតថា "ឯទីបំផុតខាងដើមនៃបុសកាលទាំង ៣ នោះមិនមានប្រាកដឡើយ" ។

កាលវេលាដែលយើងតែងកំណត់អតីត បច្ចុប្បន្ន អនាគតបាន ព្រោះយើងជាប់ជំពាក់ដោយតណ្ហា មានការប្រកាន់មាំក្នុងខ្លួនថាជាធម្មជាតិជាប់លាប់ចិត្តថេរ តាមបរមត្ថសច្ចៈ គេពុំអាចកំណត់នូវកាលបានឡើយ កាលបើដូច្នោះ គេនឹងមានការផ្លាស់ប្តូរពីនេះទៅនោះ បើពោលពីឆ្នាំវិញ មានការផ្លាស់ឆ្នាំចាស់ចូលឆ្នាំថ្មីដែរឬទេ? ឃើញថាពុំមានដោយពិត ព្រោះថាបើមានការផ្លាស់ប្តូរមែន គួរមានអ្វីដែលទៀងទាត់ជាគោលចារិកពីរបែប ទើបយើងអាចសំគាល់បានថាគោល "ក" ផ្លាស់ប្តូរទៅជា "ខ" ។ យើងនឹងយកគ្រឿងទឹកទន្លេមកជាគ្រឿងឧបមាទៀត យើងមិនអាចនឹងបញ្ជាក់បានថា ក្នុងពេលណាទឹកទន្លេផ្លាស់ប្តូរទៅជាចំហាយទឹក ពីចំហាយទឹកមកជាទឹកវិញបានឡើយ ។

សូមទាញគ្រឿងឧបមាមកបញ្ជាក់នូវគោលការណ៍នេះឲ្យជាក់ស្តែង ពេលភ្លៀងយើងឃើញទឹកហូរចាកតាមរងស្បូវ ជាសរសៃឬជាខ្សែតូចធំចុះទៅដី ដោយមំសចក្ខុសាមញ្ញរបស់យើង យើងមើលទៅឃើញច្បាស់ជាខ្សែទឹកមួយខ្សែជាប់លាប់ខ្ជាប់ខ្ជួន តាមពិតពុំមែនដូច្នេះទេ

ខ្សែទឹកនោះប្រកបដោយរូបធាតុល្អិត ៗ កំរើកញាប់ញ័របន្តគ្នាយ៉ាងឆាប់រហ័ស រអិលទៅប្រដេញគ្នាទៅ ហូរទៅមិនដាច់ ព្រឹត្តិការណ៍នេះនឹងសង្កេតឃើញច្បាស់ដល់ពេលកាំងភ្លៀង ខ្សែទឹកពីមុននោះត្រឡប់ជាតំណក់ទឹកស្រក់តក់ ៗ បន្តគ្នាឃ្លាតឆ្ងាយពីគ្នា ៗ ឯកង់តំណក់នីមួយ ៗ មានតំណក់តូច ៗ ជាច្រើន ហើយមានចន្លោះឃ្លាតពីគ្នាយ៉ាងល្អិត ដែលភ្នែកយើងកំណត់សំគាល់ពុំបាន ដោយហេតុនោះឯង ទើបមានកង់ភាសាយើងថា "ភ្លៀងដាច់គ្រាប់" ៗ ឯគ្រាប់ភ្លៀងនេះឯងបានបរវិលវង់ចុះឡើងដូចបានពោលខាងលើអំពីទឹកទន្លេ ពពក ទឹកទន្លេ កង់វង់ដែលវិលនោះ តើយើងអាចនឹងទុកគ្រាប់ភ្លៀងណានៅមុន ណានៅកណ្ដាល ណានៅខាងចុងបានឬទេ? ឃើញថាពុំបានដោយប្រាកដនឹងកំណត់បានលុះត្រាតែយើងបញ្ឈប់គ្រាប់ភ្លៀងណាមួយឲ្យនៅនឹងតែមួយកន្លែង ដែលយើងមិនអាចនឹងធ្វើបាន ព្រោះគ្រាប់ភ្លៀងមានប្រក្រតិភាព ត្រូវកំរើកត្រូវវិលទៅជានិច្ច ៗ

បញ្ចប់សេចក្ដីទៅ លោកនេះជាធាតុកូតនៃថាមពលដែលកំរើកញាប់ញ័រដោយឆាប់រហ័សគ្មានឈប់ឈរ បតិបត្តិការទៅតាមប្រសិទ្ធិភាពរបស់ធាតុ មានការផ្សំរូបធាតុ កំចាយរូបធាតុជាកម្មវត្ត លោកនេះតែងហូរទៅមិនដាច់ ដូចក្រសែទឹកដែលរលកមួយញាំងរលកមួយឲ្យកើត រលកនោះញាំងរលកដទៃឲ្យកើតជាលំដាប់ត ៗ គ្នា ឲ្យឃើញជាខ្សែទឹក

ហូរជាប់ៗគ្នាដោយអំណាចសន្តតិ កំរើកចុះឡើងវិលវល់រកដើមកំណើត ពុំឃើញទេ ។

ព្រឹត្តិកម្មដែលយើងសង្កេតឃើញ ក្នុងចក្រវាឡខាងក្រៅយ៉ាងណា ព្រឹត្តិកម្មនោះ ក៏មានក្នុងរូបរាងកាយរបស់យើងយ៉ាងនោះដែរ ព្រោះរូបរាងកាយនេះជាតួលោកធាតុមួយហៅថាលោកធាតុខាងក្នុង លោកធាតុនេះប្រកបដោយប្រជុំធាតុ ២ ប្រភេទផ្សំផ្គុំគ្នា គឺនាមធាតុនឹងរូបធាតុ នាមធាតុនឹងរូបធាតុ ដូចធាតុដទៃក្នុងលោក ផ្សំផ្គុំគ្នាជានាមធម៌នឹងរូបធម៌ កំរើកញាប់ញ័រមិនឈប់ ទៅតាមការសម្ពន្ធនៃធាតុផ្សេងៗ ជាតួសង្ខារតាក់តែងឲ្យជាយ៉ាងនេះយ៉ាងនោះឥតស្រាកស្រាន្ត ដូច្នេះអត្តភាពជាប្រជុំកំឡាំងផ្សាយថាមពលឲ្យញាប់ញ័រជាប់តៗគ្នាទៅ កម្លាំងនោះគឺកម្លាំងធាតុ នឹងកម្លាំងអាយតនៈ កម្លាំងធាតុខាងក្នុងញាប់ញ័រស្ទុះចេញទៅ ទៅប៉ះកម្លាំងញាប់ញ័រនៃធាតុខាងក្រៅ កើតជាកម្លាំងផស្សៈញ៉ាំងចិត្តឲ្យបញ្ចេញអាការផ្សេងៗ គឺវេទនា- សញ្ញា- សំខារ- វិញ្ញាណ តណ្ហា- ឧបាទាន កម្លាំងចិត្តផ្សាយចេញទៅជាចេតនា ញ៉ាំងថាមពលឲ្យប្រតិបត្តិការផ្សេងៗគឺកម្ម ជាហេតុរុញច្រានកម្លាំងឲ្យកើតតៗគ្នាទៅ បីដូចរលកនៃទឹកដូច្នោះឯង ។ កម្លាំងទាំងនោះដាច់ដោយឡែកពីគ្នា តែទាក់ទងគ្នាដោយអំណាចសន្តតិគឺកម្មមានលក្ខណៈដូចគ្នាដូច្នេះ គឺកើតឡើងរួចរលាយទៅ កើតឡើងរលាយទៅ

ជាប់ៗគ្នា ជាការវិលវល់កង់វង់មូល គឺសង្សារចក្រ សមដូចព្រះដ៏មានភាគសម្ដែងថា "ធម៌ទាំងឡាយមានការកើតឡើងនឹងវិនាសទៅជាធម្មតា" ។

អាការនៃកម្លាំងធាតុដោយឡែកៗ នោះឯង ដែលយើងហៅថាជីវិត ដូច្នេះជីវិតប្រព្រឹត្តទៅមិនដាច់តាមប្រសិទ្ធភាពរបស់ធាតុបួនមានពល ពុំមែនជាជីវិតដាច់លាច់ទៀងទាត់ទេ ហើយមានប្រមាណតិចៗ ក្នុងវិសុទ្ធិមគ្គលោកសម្ដែងថា:

"តាមបរមត្ថសច្ច អាយុជីវិតនៃសត្វមានប្រមាណតិចណាស់ ស្ថិតនៅបានត្រឹមមួយខណៈចិត្តប៉ុណ្ណោះ កង់នៃរថដែលវិលទៅតែងសង្កត់តែលើបំណុចមួយនៃកង់យ៉ាងណាមិញ ជីវិតនៃសត្វរស់នៅបានត្រឹមមួយខណៈចិត្តយ៉ាងនោះដែរ និមិត្តតែខណៈចិត្តនោះរលត់ សត្វក៏ឈ្មោះថារលត់ដែរ ។

ដូច្នេះ សត្វនៃខណៈចិត្តមុន បានរស់ហើយ តែឈ្មោះថារស់នៅ ឬនឹងរស់នៅក៏ទេដែរ សត្វនៃខណៈចិត្តខាងមុខនឹងរស់នៅ តែឈ្មោះថារស់នៅហើយឬកំពុងរស់នៅក៏ទេដែរ សត្វនៃខណៈចិត្តនេះកំពុងរស់នៅ តែឈ្មោះថារស់នៅហើយ ឬនឹងរស់តទៅទៀតក៏ទេដែរ ។ ។

តាមសេចក្ដីខាងលើនេះ សត្វរស់នៅបានត្រឹមមួយខណៈចិត្ត ៦ ខណៈចិត្តនេះ តាមគម្ពីរអភិធម្ម មនវិកាសសាស្ត្រ មានចំនួន ៦ ៨០០-០៩៩-៩៨០ ក្នុង ១ ថ្ងៃ ២៤ ម៉ោង ឯខណៈទាំងឡាយតែងកើតទៀងនឹង

វិនាសទៅគ្រប់ខណៈចិត្ត ដូច្នេះ ក្នុងខ្លួនដែលសំគាល់ថាយើងនោះ ក្នុង ១ ថ្ងៃមានសត្វចំនួន ៦.៤០០.០៩៩.៩៨០ ដែលកើតស្លាប់កើតស្លាប់តៗគ្នាមកជាប់ទាក់ទងគ្នាដោយអំណាចកម្ម កាលបើដូច្នោះ យើងមិនអាចនឹងនិយាយតាមសេចក្ដីពិតបានថា ពីម្សិលមិញខ្ញុំនៅឧដុង ថ្ងៃនេះនៅភ្នំពេញ ថ្ងៃស្អែកនៅកំពតបានឡើយ ព្រោះសត្វដែលរស់កាលពីម្សិលមិញ ពុំបានរស់នៅក្នុងថ្ងៃនេះទេ ឯសត្វដែលនឹងរស់នៅក្នុងថ្ងៃស្អែកពុំទាន់រស់នៅទេ សត្វជាអនេកដែលកើតស្លាប់តៗគ្នាក្នុងតួបុគ្គលមួយរូបពុំបានផ្លាស់ប្ដូររូបពីសត្វមួយទៅសត្វមួយទេ ព្រោះហេតុនោះ ទើបព្រះពុទ្ធសាសនាបដិសេធការផ្លាស់ប្ដូររូបនៃព្រលិងចិតបែរដូចការចូលចិត្តក្នុងលទ្ធិព្រាហ្មណ៍ ។

សូម្បីបើសត្វជាច្រើនបានកើតស្លាប់តៗគ្នាក្នុងតួបុគ្គលមួយរូបៗហើយសត្វទាំងនោះពុំបានផ្លាស់ពីមួយទៅមួយក៏ដោយ សត្វទាំងនោះគង់ជាប់ខ្សែស្រឡាយជាមួយគ្នាដោយអំណាចកម្ម ព្រោះសត្វអស់នោះជាបាតុ-ភូតនៃថាមពលរបស់កម្ម បដិកិរិយានៃថាមពលនោះនៅជាកម្លាំងកំរើកញាប់ញ័រតៗ ទៅមិនដាច់ជាតួវិបាក ប្រកាសចេញជាផលតាមប្រសិទ្ធ-ភាព ។ ក្នុងមិលិន្ទបញ្ហា មានសេចក្ដីប្រៀបធៀបដូច្នេះ “ប្រទីប ១ ដែលគេដំកល់ទុកមានអណ្ដាតរុងរឿងនៅអស់រាត្រី ១ មិនបានក្លាយទៅជាប្រ-ទីបដទៃទេ សូម្បីបើមានអណ្ដាតភ្លើងផ្សេងៗគ្នាក៏ដោយ ព្រោះជា

អណ្ដាតភ្លើងប្រព្រឹត្តតៗ គ្នាចេញពីប្រទីបតែ ១ មានសេចក្ដីប្រៀបយ៉ាងណា ក៏ធម្មសន្តតិ គឺគ្រឿងតនៃរូបធម៌និងនាមធម៌របស់សត្វដែលកើតមកនោះ សឹងមានដំណនៃរូបធម៌និងនាមធម៌ តែងតគ្នាតែ ១ ដូចគ្នាមានសេចក្ដីប្រៀបយ៉ាងនោះដែរ" ។

ដោយអំណាចការចងរស់គឺតណ្ហាគ្រប់សង្កត់ យើងក្រាញក្នុងសក្កាយទិដ្ឋិយល់ថា ទោះមានការប្រែប្រួលជុំវិញខ្លួនក៏ដោយគង់មានអ្វីមួយជាប់លាប់ថិតថេរក្នុងខ្លួនយើងដែរ ជាហេតុនាំឲ្យយើងសំគាល់ថា នេះជាយើង នោះមិនមែនយើង កើតការប្រឆាំងគ្នារវាងយើងនឹងមិនមែនយើង ជាប់ជំពាក់ក្នុងធម៌ជាគូមានក្ដៅ-ត្រជាក់ ស្អប់-ស្រឡាញ់ជាដើម ជាប់ក្នុងអំណាចកាលវេលា វិលវល់ចុះឡើងក្នុងសង្សារចក្រ ។

ដូច្នេះ លោកនេះតែងហូរទៅមិនដាច់ អាយុជីវិតសត្វទាំងឡាយប្រព្រឹត្តតៗ គ្នាជាធម្មតា គ្មានអ្វីនៅនឹងតែមួយកន្លែងចាំកំណត់ អតីត បច្ចុប្បន្ន អនាគតទេ ប្រព្រឹត្តទៅកំរើកញាប់ញ័រទៅហូរទៅតាមច្បាប់បច្ចយាការគឺបដិច្ចសមុប្បាទធម៌ បុរង់វិលតែមួយ ពុំមានឆ្នាំចាស់ឆ្នាំថ្មីសំរាប់សត្វទេ មានតែខណៈដែលកំពុងរស់នៅហើយហូរទៅប៉ុណ្ណោះ ដោយហេតុនោះ យើងនឹងតាំងសេចក្ដីសង្ឃឹមលើឆ្នាំថ្មីក៏ពុំបានផលសមដូចសេចក្ដីប្រាថ្នាទេ ព្រោះការសង្ឃឹមបែបនោះ ជាការប្រកាន់លើអ្វីដែលទៀងទាត់ កាលគ្មានអ្វីជាទៀងទាត់ហើយ ក៏នឹងខុសចាកបំណងដោយ

ពិតប្រាកដ  ឃើញថាការដកចិត្តឲ្យផុតពីសក្កាយទិដ្ឋិជាហេតុឲ្យផុតពីកណ្តាប់ដៃនៃកាលវេលា  ផុតពីការវិលវល់ក្នុងសង្សារវដ្តផុតពីធម៌ជាគូ (និរទ្វន្ទ) ។

តែការដកចិត្តចាកស្រឡះពីការប្រកាន់ខ្ជាប់ក្នុងខ្លួនថា  នុះជារបស់ខ្លួន នុះជាខ្លួន នុះជាខ្លួនរបស់ខ្លួនជាដើម កម្រនឹងធ្វើបានណាស់ ព្រោះខ្លួននេះ  ជាទីស្រឡាញ់ពេញចិត្តរបស់យើងក្រៃលែងជាងវត្ថុដទៃទាំងអស់ក្នុងលោក  កាលបើដូច្នោះគួរយើងរក្សាខ្លួននោះឲ្យបានល្អឲ្យសមជាទីស្រឡាញ់ពិត ៗ ដោយវៀរចាកនូវអំពើអាក្រក់ដែលជាហេតុនាំឲ្យកើតផលអាក្រក់គឺខ្លួនអាក្រក់  លុះសូនខ្លួនបានល្អហើយ  គួរគប្បីបំបាត់នូវហេតុល្អដែលឲ្យផលល្អគឺខ្លួនល្អនោះទៀត  ព្រោះខ្លួននេះតែងជាប់ជំពាក់ក្នុងភពក្នុងការកើត ឈឺ ចាស់ ស្លាប់  គប្បីតែញុំាងចិត្តឲ្យនឿយណាយចាកខ្លួនប្រាសចាកជំរេគលុះដល់វិមុត្តិ  ឈ្មោះថាបានបំពេញនូវករណីយ-កិច្ចសព្វគ្រប់ហើយ  ពុំមានករណីយកិច្ចដទៃក្រៅពីនោះទៀតឡើយ ឈ្មោះថាអស់ហើយនូវជាតិ ឈ្នះនូវការជំពាក់ក្នុងកាលវេលា  នូវការវិលក្នុងសង្សារចក្រ  នូវមច្ចុរាជ ។

យើងតោងកុំភ្លេចថា  កាលវេលាតែងទំពាស៊ីសព្វសត្វទាំងឡាយព្រមទាំងខ្លួនឯងផង  កាលវេលារមែងហូរល្ហូរទៅឥតស្រាកស្រាន្តយ៉ាងឆាប់ ពុំមាននរណាអាចទប់ឃាត់ពេលវេលាឲ្យឈប់ចាំខ្លួនបំពេញកិច្ចនេះ នោះ

ហើយសិនបានឡើយ  កាលកន្លងទៅហើយពុំមានអ្វីអាចនឹងទាញឲ្យថយក្រោយវិញបានទេ  ព្រោះហេតុនោះ  យើងគោងប្រញាប់ប្រញាល់បំពេញកិច្ចការដែលត្រូវធ្វើដោយរួសរាន់ទាន់ពេល  ត្រូវបេះប្រើកាលដែលប្រព្រឹត្តយ៉ាងរហ័សនោះឲ្យមានប្រយោជន៍គ្រប់គ្រាន់បរិបូណ៌ចំពោះខ្លួននឹងអ្នកដទៃ  កុំស្រវឹងក្នុងវ័យថាពុំទាន់ជាអ្វី  កុំប្រហែសធ្វេសអាងផាប់ឆ្នាំ  រង់ចាំឆ្នាំថ្មីសោះឡើយ  ព្រោះកាលវេលាតែងកន្លងទៅគ្រប់ៗ ខណៈចិត្ត ៗ  លុះបានដឹងច្បាស់នូវអាការមិនឋិតថេរនៃកាលវេលានឹងវត្ថុនានាក្នុងលោក  មានសេចក្ដីតក់ស្លុតភ័តភ័យចំពោះអចិរភាពបែបនោះហើយ  កុំបីស្រែកប្រកាសប្រាប់ខ្លួនឯងនឹងគាថា "នៃវើយកាលវេលាកន្លងទៅឆាប់រហ័សណាស់  គួរយើងប្រញាប់ប្រញាល់ឡើងក្រេបរសជាតិកាមារម្មណ៍ឲ្យទាន់ពេល  កុំឲ្យខកខាននាំស្ដាយក្រោយ" ព្រោះការប្រកាសបែបនោះ  ជាគតិនៃជនពាលធ្វើខ្លួនឲ្យវង្វេងឲ្យជាប់ក្នុងសេចក្ដីឈឺចាស់ស្ងាប់ ៗ  តែគួរប្រញាប់ប្រញាល់បំពេញសេចក្ដីល្អគ្រប់ប្រការ  ដើម្បីកសាងខ្លួនឲ្យបានដល់ត្រើយនៃសន្តិដ៏ឧត្ដម ៗ

សូមកាលវេលាកុំកន្លងយើងរាល់គ្នា !

សុភមិត្ត

# វិសាខបន្តូលសម័យ

ប៉េលប៉ាលប៉ើងប៉ុងក្នុងសមុទ្រ　　ផ្រាលផ្រើបំផុតផតខែត្រ័ណ្ឌ
ក្នុងយប់ងងឹតឥតសែងច័ន្ទ្រ　　សត្វលោកណែនណាន់ហែលប្រញាយ ៗ
ទុក្ខអើយសែនទុក្ខមុខហ្មងសៅ　　ទិសទីខ្ឈលខ្មៅក្តៅក្រហាយ
ពុំអាចពិនិត្យទីដិតឆ្ងាយ　　សោប់សោយកាយក្រំាក្រា ៗ
រលករលាំគគ្រំាគ្រេង　　បោកលេងជាល្បែងវែងវេទនា
ក្រឡាប់ផ្កាប់ផ្ងារសព្វវេលា　　កំព្រាអ៊ីម៉ុះពុំបេះស្រាន្ត ៗ
វិលដូចខ្សែពានគ្មានកំណត់　　ក្នុងសង្សារវដ្តបែនបត់ប្រាណ
ខ្វក់ខ្វល់ធុញថប់សព្វដែនដាន　　រំខានក្នុងចិត្តឥតទីពឹង ៗ
ឱត្រើយស្ងប់ស្ងាត់បាត់ទៅណា　　ម្តេចមិនមេត្តាប្រាប់ដំណឹង
ឲ្យយើងហែលហបហត់ទាំងម៉ឹង　　ខំប្រឹងឥតផលដល់គិតសោះ ៗ
ឱសត្វរងោកជោគជាំទុក្ខ　　សត្រូវគ្រប់មុខគ្មានបន្ធោះ
វេងកម្មចាំជាប់គ្មានរដោះ　　ស្រណោះស្រណោកសោកនៅនិត្យ ៗ

រាត្រីមួយល្អះល្អអនេក　　ចន្ទ្របែងចាំងមេឃភ្លឺផ្លេកពិត
បីដូចអាវុធមុតស័ក្តិសិទ្ធ　　កាប់ផ្កាងងឹតដោយរស្មី ៗ
បង្ហាញត្រើយត្រាណដល់សព្វសត្វ　　កំចាត់ឧបទ្រពក្នុងភពបី
គឺថ្ងៃវិសាខបុណ្ណមី　　សុកតិថីល្បីអស្ចារ្យ ៗ
ថ្ងៃដែលព្រះពុទ្ធទ្រង់ប្រសូត　　រុងរឿងរហូតគ្រប់ប្រការ

ក្នុងលុម្ពិនីទីមហោឡារ   ព្រះរាជកុមារចេញចាកផ្ទៃ ។
ថ្មើរពីរជំហានឈានចេញចរ   កាន់ទិសឧត្តរល្អប្រពៃ
ជាតិជាបុរសអាជានេយ្យ   ទ្រង់លៃបន្លឺព្រះវាចា ។
‘ អគ្គអញឯងនេះឯកសក្តិសម   ឧត្តមបមកពម្ពប់លោកា”
ពោលក្នុងចំណោមពួកទេវ្តា   ដែលចាំត្រៀបត្រាគាល់លោកនាថ ។
ពេលនោះអស្ចារ្យញ័រផែនដី   លាន់ឮតន្ត្រីសព្ទពិណពាទ្យ
ប្រាកដរស្មីឆ្លុះព្រោងព្រាត   មួយម៉ឺនលោកធាតុភ្លឺឥតសល់ ។
ឯការកើតមាននៅក្នុងលោក   នៃព្រះមានជោគក្រុបានដល់
មិនងាយអស់សត្វបានយង់យល់   ព្រះកាយទសពលក្រាបអញ្ជលី ។
ឥឡូវព្រះអង្គទ្រង់ឧប្បត្តិ   ស្រោចស្រង់សព្វសត្វទូទិសទី
កំក្រើកញាប់ញ័រខ្ញ័រប្រែថពី   សមអស់ពៃរីខ្លាតចេញឆ្ងាយ ។
ដោយគុណតេជះព្រះពុទ្ធអង្គ   ស្តេចទ្រង់ប្រសូតប្រសើរសាយ
សូមសព្វសត្វបានសំរាន្តកាយ   រសាយណាយពីពៀរវេរា ។
សំរាំងតាំងចិត្តប្រណីតស្អាត   ឈប់លែងព្យាបាទអាឃាតគ្នា
មូលមិត្តស្និទ្ធស្នាលរួមសមគ្គា   ចំរើនជោគជាជានិច្ចកាល ។
អស្ចារ្យទីពីរនៃតិថី   វិសាខបុណ្ណមីរស្មីត្រចាល
ប្រវត់ស្រោចស្រប់រត្តិកាល   វិសេសវិសាលឥតប្រៀបបាន ។
គ្រានោះព្រះបរមពោធិសត្វ   កំចាត់កិលេសចាកសន្តាន

ទ្រង់បានសម្រេចពោធិញ្ញាណ បន្លឺឧទានដោតជ័យជា ។
"កាលតថាគតរកជាងផ្ទះ ពុំជួបប្រទះសោះឡើយណា
រន្ធត់ក្នុងវដ្ដសង្សារ កើតជាតិទុក្ខាគួរស្អប់ស្អែង ។
រីឯនៃជាងផ្ទះគឺតណ្ហា អញបានយល់ប្រាកដស្ដែង
ពេលនេះអាអស់ពេលតាក់តែង តាំងផ្ទះសម្បែងឲ្យអញហើយ ។
បង្គង់ផងអាក៏បែកបាក់ ដម្បូលផ្ទះធ្លាក់ឥតសល់ឡើយ
ចិត្តអញប្រាសចាកសង្ខារហើយ របូតដល់ត្រើយតណ្ហាក្ស័យ" ។
ដោយបុទ្ធិតេជះព្រះមុនី បានសម្ពោធិលើសកតត្រ័យ
អព្ភូតធម៌អស្ចារ្យក្រៃ វិស័យព្រះពុទ្ធវិសុទ្ធញាណ ។
សូមឲ្យសព្វសត្វបាត់សោកសៅ មួយម៉ោងក្ដៅពេលក្នុងសន្ដាន
ព្រោះភ្លើងតណ្ហាឈប់រំខាន ដល់ទីក្សេមក្សាន្ដសំពន្ដចិត្ត ។
អស្ចារ្យទីបីនៃតិថី វិសាខបុណ្ណមីល្អប្រណីត
ព្រះអង្គីរសខ្ពស់វិចិត្រ សណ្ឋិតនៅក្រោមដើមសាលព្រឹក្ស ។
ឯសាលទាំងគូក៏ចេញផ្កា អកាលបុប្ផាច្រើនពន្លឹក
មន្ទារបុស្សធ្លាក់សន្ធឹក គគឹកចាកសួគ៌ជាសក្ការ ។
ព្រះអង្គថ្លែងផ្ដាំឲ្យចាំជាក់ "នែអស់សាវកឯសង្ខារ
តែងសូន្យវិនាសឥតខ្លឹមសារ ចូរញ៉ាំងកិច្ចការដោយឧហាត ។
ប្រយោជន៍នៃខ្លួននឹងអ្នកផង កុំឲ្យមានហ្មងបរិសុទ្ធស្អាត

ដោយនូវសេចក្ដីមិនប្រមាទ" នេះជាគុណទីអវសាន ។
ប្រដៅចប់ស្រេចព្រះមុនិន្ទ ចមពិន្ទុស្ដេចយាងចូលនិព្វាន
ផែនដីកក្រើកសព្វស្ទើរសាន ហាក់មានវិញ្ញាណអាក់អួលផ្សា ។
មុខគួរស្រណោះព្រះភគវន្ត អគ្គអរហន្តជាសាស្ដា
និព្វានបង់បាត់រូបកាយា សល់តែសាសនាទុកវែងឆ្ងាយ ។
សូមគុណតេជះព្រះធម៌ថ្លៃ ជួយកែនិស្ស័យសត្វទាំងឡាយ
ឲ្យលះពុតព្យសន៍អស់សោកស្ដាយ ខ្វល់ខ្វាយសំរេចសេចក្ដីសុខ ។
កុំបីប្រហែសធ្វេសប្រមាទ ដើមអាទ៌បង្កបង្កើតទុក្ខ
ដាប់ជាដំណាតទៅមុខ អុកឡុកកើតស្ទាប់ពុំមានអាក់ ។
ឲ្យមានសតិតាំងខ្ជាប់ខ្ជួន យោងខ្លួនឲ្យរួចពីអន្ទាក់
នៃពៅក្រុងមារចោរអប្បល័ក្ខណ៍ សមសក្ដិពុទ្ធសាសន៍រុងរឿងបុទ្ធ ។
ពេលនេះប្រចួបខួបតិថី វិសាខបុណ្ណមីព្រះវិជិត
ប្រសូតិត្រាស់ដឹងនិព្វានពិត កំចាត់ងងឹតពីក្នុងលោក ។
គួរយើងជាពុទ្ធមាមក: ធ្វើសក្ការៈដោយប្រយោគ
គោរពបូជាព្រះមានជោគ ប្រកបអធិយោគសាងកុសល ។
ថ្ងៃនេះឯងហើយព្រះជិនស្រី គង់ក្រោមរស្មីចន្ទ្រនិមិល
ទៀបឆ្នេរនេរញ្ជរាជល ទសពលផ្ចាលផ្ចាញ់មារប្រែ ។
ថ្ងៃនេះជាថ្ងៃជោគបវរ ដល់សត្វនិករទាំងភពត្រៃ

ព្រះពុទ្ធប្រទានប្រទីបថ្លៃ    ទុកដល់សព្វថ្ងៃគឺព្រោងព្រាត ។
ប្រទីបសន្តិត្រជាក់ក្ដាត់    នាំសត្វដល់ត្រើយឥតឃ្លាឃ្លាត
ប្រគល់ឲ្យសត្វក្រេបរសជាតិ    ជាញាតិមិត្តភក្តិស្ន័គ្រស្នាគម ។
ប្រទីបអម្ពុតដូចអាវុធ    ប្រសើរមុះមុតឯកឧត្តម
បញ្ចេញកិលេសទុក្ខក្រៀមក្រំ    អនិដ្ឋារម្មណ៍ឲ្យខ្លាត់ខ្លាយ ។
យើងបានប្រទីបបំភ្លឺហើយ    កុំឆើយផ្ដេសផ្ដាសប្រាសចេញឆ្ងាយ
វិលវកងងឹតរូបវិតកាយ    ខ្វល់ខ្វាយអើពើធ្វើតែបាប ។
បំណាច់លើកខ្លួនជាពុទ្ធសាសន៍    គួរខ្លាសការកេរ្តិ៍កុំឲ្យសាប
តែធ្វេសសត្រូវគំរាមជាប    ពុំងាយបង្ក្រាបឲ្យបាញ់ទេ ។
កើតទាន់សាសនាពេញហៅក្រ    ហេតុបានសាងល្អពីបុព្វ
កុំឲ្យខកខានខ្ចបទទេ    គួរវេគួរវិះយោងអាត្មា ។
ថ្ងៃនេះគួរចាត់ចែងបូជា    ព្រះភគវាដោយភក្ដា
តែការគោរពបែបនេះណា    ព្រះអង្គត្រាស់ថាពុំប្រពៃ ។
ឯគារវៈដ៏ប្រសើរ    គឺដើរតាមក្រោយព្រះធម៌ថ្លៃ
ប្រតិបត្តិខាត់ចិត្តរៀងរាល់ថ្ងៃ    បោលពុតព្រៃផ្សៃដោយព្យាយាម ។
ឯព្រះជិនស្រីល្បីតេជះ    មានជ័យជំនះគ្រប់សង្គ្រាម
អង្គអាចក្លាហានគ្រប់ៗយាម    ឈ្នះគ្មានរំមរាមវិលត្រឡប់ ។
ពួកយើងរាល់គ្នាជាទាសៈ    លោភៈទោសៈមោហៈសព្វ

វែកពុនធ្ងន់ខ្លួនក្នុងធុញថប ព្រោះស្អប់ស្រឡាញ់ចាញ់គ្រប់ឋាន ៗ
កិលេសនេះហើយជាសត្រូវ មកពាំងផ្លូវក្រផ្ចាញ់បាន
ផ្ដន្ទាយាយីញាំញីប្រាណ ឥតស្រាន្តទំនេរពេលណាឡើយ ៗ
បើយើងចង់បានជាអ្នកឈ្នះ គួរខ្នះគួរខ្នែងកុំកន្តើយ
បង្អន់កិលេសឲ្យធូរស្បើយ ធូរហើយទំលាយឲ្យលាញបង់ ៗ
បំណែកខាងជ័យដទៃទៀត ដោយបៀតបៀនគ្នាពុំបញ្ចង់
អាចប្រែចាញ់វិញឥតបង្អង់ ផ្ចិតផ្ចង់ផ្ចាញ់ខ្លួនទើបចិញ្ចែង ៗ
រំលត់រំលើងភ្លើងកិលេស វិសេសធ្ងន់ផុតទុក្ខបំបែង
ចិត្តដល់វិមុត្តិប្រែច័ក្សបែង គួរស្វះគួរស្វែងយកឲ្យបាន ៗ
ដោយគុណតេជៈព្រះបារមី វិសាខតិថីសូមក្សេមក្សាន្ត
សន្តិស្រោចស្រប់សព្វដែនដាន មនុស្សសត្វសព្វឋានបានសុខា ៗ
សូមឲ្យប្រទីបល្អើតឆាយ បំភ្លឺសុះសាយផ្ទេរផលសា
ឲ្យសត្វធ្ងន់ផុតសង្សារ សមដូចប្រាថ្នាគ្រប់គ្នាអើយ ៗ

ហេង - យ៉ាន់

# វិសាខបូជាគាថា

ឰដ៏អតីតកាលដែលកន្លងរំលងទៅចំនួន ២៥៧៤ ឆ្នាំ ហើយ (បើគិតមកទល់នឹង ព. ស. ២៤៩៤ នេះ, នៅនាសួនលុម្ពិនីវនោទ្យានក្នុងប្រទេសដែលសព្វថ្ងៃនេះមាននាមថា នេប៉ាល់ ទៀបភ្នំហិមពាន្ត ក្នុងដែនឥណ្ឌា (ខាងលិចប្រទេសកម្ពុជាយើង), ព្រះបរមពោធិសត្វ កាលសោយព្រះជាតិជាសន្តុសិតទេវបុត្ត បានទទួលសេចក្តីអញ្ជើញរបស់ពពួកទេវតា ច្យុតចុះចាកស្ថានតុសិតសួគ៌ទេវលោក មកចាប់បដិសន្ធិក្នុងឧទរព្រះនាងសិរីមហាមាយាទេវី ឯកអគ្គមហេសីនៃព្រះបាទសុទ្ធោទនមហារាជ, ព្រះចៅក្រុងកបិលពស្តុ, ទ្រង់ស្ថិតនៅគ្រប់កំណត់ទសមាសហើយ ក៏បានប្រសូតក្នុងទីនោះដែលជាចន្លោះនៃដែនពីរ គឺដែនសក្កៈនិងទេវទហៈ

ក្នុងថ្ងៃសុក្រពេញបូណ៌មី គឺថ្ងៃជាមង្គលនៃខែវិសាខឆ្នាំច ។

ក្នុងគ្រាដែលទ្រង់ប្រសូតមានហេតុជាមហស្ចារ្យ ថាទ្រង់មានព្រះកាយដ៏ល្អបរិសុទ្ធ ចេញចាកឧទរព្រះវរមាតា ហាក់ដូចជាព្រះធម្មកថិកចុះចាកគ្រែធម្មាសនៈ បន្ទាប់មក ទ្រង់ប្រថាប់ឈរព្រះភក្ត្រឆ្ពោះទៅកាន់ឧត្តរទិស ស្តេចលីលាទៅបានប្រាំពីរជំហាន មានផ្កាឈូកផុះចេញអំពីផែនប្រថពីទ្រទ្រាប់ព្រះបាទ ។ នៅពេលនោះ ទ្រង់បានបន្លឺអាសភិវាចាជាបាទព្រះគាថាថា:

"អគ្គោហមស្មិ លោកស្មិំ សេដ្ឋោ ជេដ្ឋោ អនុត្តរោ
អយញ្ច អន្តិមា ជាតិ នត្ថិទានិ បុនព្ភវោ

ក្នុងលោកមានតែអញជាឯកអគ្គ ប្រសើរអស់គ្រប់បំបង់លើសគេ
តទៅពីនេះគ្មានភពថ្មីទេ ជាតិពីបុព្វផុតត្រឹមហ្នឹងហើយ" ។

ព្រះឧទានគាថានេះ សឲ្យឃើញថាព្រះអង្គប្រសូតមកភ្លាម ដឹងព្រះអង្គជាក់ថានឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោក នឹងបានជាសាស្តាឯកប្រៀនប្រដៅវេនេយ្យសត្វ ជាវិសេសបម្បង់ឥតមានសាស្តាណាម្នាក់ផ្ទឹមស្មើ លុះដល់កំណត់ទ្រង់នឹងរំលត់ខន្ធចូលកាន់ព្រះបរមនិព្វានសោយឯកន្តសុខដាច់ផុតអស់ជាតិកំណើត ផុតរលត់ឥតមានភពថ្មី តទៅទៀតឡើយ ។

កាលព្រះបរមពោធិសត្វ មានព្រះជន្មគ្រប់គ្រាន់ចំនួន ១៦ ព្រះវស្សាទ្រង់បានទទួលព្រះបរមាភិសេក ជាមួយនឹងព្រះនាងពិម្ពាយសោធរា ជារាជធីតានៃព្រះបាទសុប្បពុទ្ធ សោយសិរីរាជសម្បត្តិស្នងព្រះវររាជបិតា ជាសុខក្សេមក្សាន្តក្រៃនរណានឹងបានដូចព្រះអង្គឡើយរៀងរហូតអស់ ១៣ ព្រះវស្សា ទើបទ្រង់ពិចារណានឹកគិតដល់សេចក្តីទុក្ខរបស់ពពួកសត្វ គឺជាតិ ជរា ព្យាធិ មរណៈ ក្នុងពេលដែលទ្រង់យាងចេញទៅប្រពាតឧទ្យាន ទ្រង់បានជួបប្រទះនឹងទេវទូតទាំងបួនដែលទេព្តា

និម្មិតជាមនុស្សចាស់, ឈឺ, ស្លាប់នឹងអ្នកបួស, ទ្រង់ក៏បានជ្រាបច្បាស់ថា មានតែបុគ្គលអ្នកស្ថិតនៅក្នុងឧត្តមភេទនេះទេ ទើបមានទំនងស្រួលល្មមនឹងស្វែងរកមធ្យោបាយ កំចាត់បាននូវសេចក្តីទុក្ខទាំងបួនកងជាដើមនេះ ដែលតែងញាំញីពពួកសត្វទាំងអស់ឥតមានរើសមុខ ។

លុះទ្រង់បានជ្រាបច្បាស់នូវទំនងនេះហើយ ទើបទ្រង់លះបង់រាជសម្បត្តិយសបរិវារ, នូវព្រះនាងពិម្ពាយសោធរាជាឯកអគ្គមហេសីនឹងព្រះប្រិយបុត្រព្រះនាមរាហុលដែលទើបនឹងប្រសូតពេញជាទីបណ្តាប់បណ្តូលព្រះហឫទ័យស្មើរតែព្រះអង្គលះកាត់អាល័យពុំរួច សឹងមានឧទានវាចាដែលព្រះអង្គកំពុងគង់ក្រសាលក្នុងឧទ្យាន កាលទ្រង់បានជ្រាបដំណឹងអំពីពួកសេវកាមាត្យដែលចូលទៅក្រាបទូលថា ព្រះរាជឱរសប្រសូតហើយ, ទ្រង់បន្លឺព្រះឧក្ការតំអូញថា “ឱរហើយ! រាហូចាប់អញបានហើយ!” គឺព្រះអង្គប្រៀបប្រដូចតួទ្រង់ទៅនឹងព្រះចន្ទ្រ ឯព្រះរាជឱរសដែលជាទីស្រឡាញ់ស្នេហ៍ស្និទ្ធឥតប្រៀបបាន ជាបំណងចង់ក្រៀកបិតាឲ្យខកពេលស្កុនដំណើរទៅរកមោក្ខធម៌ ជាឧបសគ្គស្ទាក់គំនិតមិនឲ្យលុះមគ្គផលកុសលធម៌ផ្សេងៗ នោះទ្រង់ប្រដូចទៅនឹងរាហូអសុរិន្ទ្រដែលជាសត្រូវចំពោះព្រះចន្ទ្រ តែងរួបរឹតបិទបាំងរស្មី ក្នុងពេលដែលជួបប្រទះម្តងៗ ទើបពួកសេវកាមាត្យប្រឌិតយកដំណើរហេតុនោះ សន្មតថ្វាយព្រះនាមព្រះរាជឱរសថា “ព្រះរាហុល” ។

ប៉ុន្តែទោះបីទ្រង់ប្រកបដោយបរមសុខដ៏ស្តុកស្តម្ភនឹងចំណងដ៏មាំយ៉ាងនេះក៏ដោយ គង់ព្រះអង្គខំប្រឹងលះកាត់លុះត្រាតែបានជួបព្រះរាជបំណង ចេញទៅបំពេញអភិនេស្ក្រមណ៍តែមួយព្រះអង្គឯង ខំប្រឹងបំពេញវត្តប្រតិបត្តិយ៉ាងតឹងរ៉ឹងឥតមានតាបសឬសិទ្ធិគ្រូអន្យតិរ្ថិយសាស្តាណាម្នាក់ផ្ទឹមស្មើបានឡើយ ។ ទ្រង់ប្រព្រឹត្តយ៉ាងនេះ មិនមែនតិចតួចឡើយ ប្រាំមួយវស្សាគត់ រិះរេបរបត់ចិត្តគំនិតគ្រប់បែបគ្រប់ទំនង ដរាបដល់ថ្ងៃពុធ ពេញបូណ៌មី ខែពិសាខ ឆ្នាំរកា ក្នុងព្រះជន្មាយុគំរប់ ៣៥ ព្រះវស្សាគត់ ទើបព្រះពិជិតមារបរមគ្រូទ្រង់ស្ដេចទៅប្រថាប់ទៀបគល់ព្រះពោធិព្រឹក្ស ដែលមានជីវិតរស់នៅដរាបដល់សព្វថ្ងៃនេះនៅត្រង់ភូមិមួយដែលឥឡូវនេះហៅថា "ពុទ្ធគយា" មិនឆ្ងាយប៉ុន្មានពីក្រុង "គយា" ។ នៅត្រង់ទីនេះ ព្រះបរមសាស្តាបានផ្ចាញ់មារព្រមទាំងពួកពលសេនាឲ្យបរាជ័យ ក្នុងវេលាព្រះអាទិត្យមិនទាន់អស្តង្គតរលត់រស្មីនៅឡើយ ហើយទ្រង់កំចាត់បង់នូវងងឹតដែលបិទបាំងបុព្វេនិវាសានុស្សតិញ្ញាណ ក្នុងវេលារាត្រីបឋមយាម, ទ្រង់ជម្រះទិព្វចក្ខុញ្ញាណឲ្យបានបរិសុទ្ធ ក្នុងវេលារាត្រីមជ្ឈិមយាម, ទ្រង់ពិចារណាដោយព្រះប្រាជ្ញាដ៏បរិសុទ្ធ នូវបច្ចយាការគឺបដិច្ចសមុប្បាទធម៌ជាអនុលោមបដិលោម ក្នុងវេលារាត្រីបច្ឆិមយាម ។ លុះដល់វេលាអរុណរះ ព្រះបរមគ្រូទ្រង់បានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណជាមហាស្ចារ្យក្នុងលោក ។

កាលដែលព្រះមហាវីរៈបានត្រាស់ដឹងហើយភ្លាមនោះ ទ្រង់បានសោយសេចក្ដីសុខយ៉ាងត្រកាល ដែលជាផលនៃសេចក្ដីព្យាយាមដ៏ធំអស់រយៈពេលប្រាំមួយឆ្នាំ ដរាបដល់ទ្រង់អត់ទ្រាំស្ងៀមពុំបាន ទ្រង់បន្លឺឧទានកថាបន្តុះបង្អាប់ផ្ចាញ់ផ្ចាលតណ្ហាជាបទគាថា ថា៖

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ
គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា

កាលតថាគតស្វែងមិនប្រទះ ជួបនឹងជាងផ្ទះពោលគឺតណ្ហា
តែងអន្ទោលកើតក្នុងសង្សារ អនេកជាតិជាទុក្ខឥតស្រាកស្រាន្ត ៗ
ឥឡូវជួបហើយអ្នកនឹងលែងបាន ធ្វើគេហស្ថានឲ្យយើងទៀងជាក់
ព្រោះយើងបានកាច់គ្រោងផ្ទះនៃអ្នក ទាំងទាញទំលាក់ដំបូលចោលហើយ ៗ
ចិត្តយើងក៏ដល់និព្វានជាត្រើយ ឥតតណ្ហាឡើយសូន្យសោះរលីង" ៗ

ព្រះឧទានកថានេះ នឹងហៅថាបឋមពុទ្ធវចនៈក៏បាន ព្រោះជាព្រះពុទ្ធដីកាដំបូងបង្អស់គឺចាប់តាំងពីពេលបានត្រាស់ដឹងមក ព្រះអង្គមិនទាន់មានព្រះពុទ្ធដីកាព្រះឧស្ឋណាមួយមុនព្រះឧទានកថានេះឡើយ ហើយ

ជាទំនៀមប្រពៃណីរបស់ព្រះពុទ្ធពីបុរាណទាំងអម្បាលខ្ជាប់ ដែលបានត្រាស់ដឹងក្នុងកាលទាំងពួង តែងទ្រង់បន្លឺដូច្នេះគ្រប់ព្រះអង្គមិនលះបង់ឡើយ ដូចយើងព្យាយាមរំប្រឹងគិតគូរកិច្ចការណ៍ណាមួយ មិនលេចស្រពិចស្រពិលសោះ អស់កាលវេលាជាយូរទើបបានសម្រេច ពេលនោះយើងក៏តែងមានសោមនស្សត្រេកអរយ៉ាងខ្លាំង ស្ទើរតែតាំងស្មារតី ក្ជាត់មាត់ក្ជាត់កបន្លឺពាក្យពេចន៍ថា យ៉ាងនេះយ៉ាងនោះដូច្នោះឯង ៗ

ក្នុងព្រះឧទានវាចានេះព្រះអង្គប្រៀបធៀបតណ្ហាគឺចំណង់, តម្រេក, សេចក្ដីប្រាថ្នា, ការអន្ទះអន្ទែងច្រាសច្រាល់ ដែលជានាមធម៌ឥតរូបរាងសណ្ឋានទ្រង់ទ្រាយពណ៌សម្បុរ ប៉ុន្តែមានអំណាចអាចនាំសត្វឲ្យមានអត្តភាពយានយកកំណើតកើតក្នុងភពថ្មីៗ ទៅមិនចេះអស់មិនចេះហើយ ជាកិលេសចងក្រៀកក្ដាប់ក្ដាំសត្វឲ្យបានសេចក្ដីទុក្ខព្រួយលំបាកច្រើនប្រការ មានជាតិទុក្ខ, ជរាទុក្ខ, ព្យាធិទុក្ខនិងមរណទុក្ខជាដើម ឲ្យត្រេកត្រអាលតែក្នុងកាមគុណទាំងប្រាំ គឺ រូប, សម្លេង, ក្លិន, រសនិងសម្ផស្ស នេះទុកដូចជារូបធម៌គឺជាងឈើអ្នកធ្វើផ្ទះ ៗ

ព្រះសព្វញ្ញូទ្រង់ប្រៀបធៀបអត្តភាពរបស់ព្រះអង្គដែលតណ្ហាជាអ្នកតុបតែងបង្កបង្កើតឡើង ទុកដូចជាផ្ទះដែលជាងឈើធ្វើឡើង ៗ

គ្រោងផ្ទះទាំងមូល ទ្រង់ប្រៀបប្រដូចទៅនឹងកិលេសដ៏សេសសល់ទាំងប៉ុន្មាន ដែលត្រាំនៅក្នុងខន្ធសន្តាន ៗ

ធម្មតាផ្ទះតែងមានដំបូលជាមេ, ជាគ្រឿងប្រកដ, ជាធំ ទើបព្រះអង្គទ្រង់ប្រៀបផ្ទឹមទៅនឹងអវិជ្ជាដែលជាបច្ច័យនៃសង្ខារ ។

ព្រះអង្គបានពិចារណាពវកេតណ្ហា នឹងអាសវក្កិលេសទាំងនោះ ឃើញច្បាស់ ដោយសម្មាសម្ពោធិញ្ញាណ ដែលព្រះអង្គខំប្រឹងបន្ទុំសន្សំមកចាប់តាំងអំពីពុទ្ធកាលនៃព្រះពុទ្ធទីបង្ករ ទើបទ្រង់ដកព្រះទ័យផុតស្រឡះលែងឲ្យជាប់ជិតជាមហើយ ផ្ដាច់ផ្ដិលជាតិកំណើតមិនឲ្យកើតមានក្នុងភពតូចភពធំតទៅទៀត ដោយការតម្កល់ព្រះហឫទ័យឲ្យតាំងក្នុងព្រះនិព្វានឥតសង្ខារ បានសម្រេចព្រះអរហត្តផលសូន្យសោះអស់តណ្ហា ប្រៀបដូចបុគ្គលកិនគ្រាប់ស្រូវបកបោលអង្កាមចេញស្រឡះហើយ យកទៅបុកបោសផាត់បន្សាត់កណ្ដកបោលទៀត ទើបយកទៅបុកជាម្សៅយ៉ាងសម៉ដ្ឋល្អ អាចយកទៅធ្វើជានំចំណីបរិភោគបានសព្វយ៉ាង លែងដុះដាលជាដើមទងពូជស្រូវតទៅទៀតយ៉ាងនោះឯង ។

ចាប់តាំងពីពេលនោះមក ព្រះពិជិតមារបរមគ្រូបានតាំងព្រះទ័យសម្ដែងធម៌ទូន្មានប្រៀនប្រដៅវេនេយ្យសត្វរហូតទៅទល់នឹងថ្ងៃដែលទ្រង់ចូលកាន់ព្រះបរមនិព្វានអស់រយៈកាលចំនួន ៤៥ ព្រះវស្សា មានការសម្ដែងធម្មចក្កប្បវត្តនសូត្រ ប្រោសព្រះបញ្ចវគ្គិយភិក្ខុ នៅនាស្ថានឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសីជាដើម រួចហើយស្ដេចធ្វើពុទ្ធដំណើរបែកផ្លូវពីព្រះបញ្ចវគ្គិយចេញទៅកាន់ទិសទីដទៃ ៗ ផ្សេង ៗ ពីគ្នាទៅប្រដៅ

មហាជនក្នុងស្រុកនិគមលំនៅជនបទនិងរាជធានីផ្សេងៗ ឲ្យបានយល់ជាក់នូវចតុរារិយសច្ច, ទ្រង់ប្រតិស្ឋានពុទ្ធបរិស័ទទាំង ៤ ពួកគឺភិក្ខុ, ភិក្ខុនី, ឧបាសក, ឧបាសិកាឲ្យឋិតនៅក្នុងព្រះសទ្ធម្មសមគួរតាមវាសនារបស់ខ្លួនៗ

មហាការុណិកោ នាថោ ព្រះបរមលោកនាថទ្រង់ប្រកបដោយមហាករុណាដ៏ធំចំពោះមនុស្សទេវតា ទ្រង់បំពេញពុទ្ធកិច្ចទាំងថ្ងៃទាំងយប់ឥតមានឈប់សម្រាកទំរាំត្រឹមណាមួយឡើយ សូម្បីក្នុងគ្រាដែលព្រះអង្គមានជន្មាយុគម្រប់៨០ឆ្នាំគត់ នៅថ្ងៃអង្គារពេញបូណ៌មីនៃខែពិសាខឆ្នាំម្សាញ់បញ្ចស័ក នៅពេលដែលទ្រង់ផ្ទំលើមញ្ចាសនៈជាទីបរិនិព្វានដោយអនុដ្ឋានសញ្ញា (ការសំគាល់កំណត់ទុកក្នុងព្រះហឫទ័យថាទ្រង់មិនក្រោកចាកទីនោះឡើយ), ទ្រង់សម្រេចសីហសេយ្យាសន៍បែរព្រះកត្រទៅខាងស្ដាំតម្រង់ព្រះសិរទៅឧត្តរទិស ក្រោមដើមសាលព្រឹក្សមួយគូក្នុងសាលវនោទ្យាននៃមល្លក្សត្រិយ៍ ជិតក្រុងកុសិនារាហើយ ក៏ទ្រង់នៅពុំទាន់អស់ព្រះហឫទ័យអាណិតពពួកសត្វទៀត, ទ្រង់ត្រៀតត្រាស់ហៅព្រះអានន្ទឲ្យចូលមកជិតហើយ ទ្រង់ត្រាស់ប្រទានព្រះបរមពុទ្ធោវាទដល់ភិក្ខុបរិស័ទឲ្យគោរពប្រតិបត្តិចំពោះធម៌វិន័យ ។ ទ្រង់ប្រតិស្ឋានធម៌និងវិន័យទុកជាសាស្ដាស្នងព្រះអង្គតមក ដោយព្រះពុទ្ធដីកាថា: "ម្នាលអានន្ទ, អំណើះតអំពីតថាគតទៅ, អ្នកទាំងឡាយ មុខជានឹងមានគំនិតថា 'ព្រះសាស្ដារបស់យើងបរិនិព្វានទៅហើយ, ឥឡូវ

យើងមិនមានសាស្ដាត្រួតត្រាយើងទៀតទេ” ពុំខាន ។ ម្នាលអានន្ទ, គំនិតយ៉ាងនេះមិនត្រឹមត្រូវឡើយ, យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថា ម្នាលអានន្ទ, ព្រោះថាធម៌និងវិន័យឯណា ដែលតថាគតបានសម្ដែងហើយ បានបញ្ញត្តហើយដល់អ្នកទាំងឡាយ, លុះអំណើះតអំពីតថាគត. ធម៌និងវិន័យនោះឯងហើយនឹងជាសាស្ដាគ្រូអាចារ្យរបស់អ្នកទាំងឡាយជំនួសតថាគតតទៅ ’ ។

លំដាប់នោះ ព្រះសព្វញ្ញូបរមគ្រូជាម្ចាស់ទ្រង់ត្រាស់ដាស់តឿនពុទ្ធបរិស័ទទាំងឡាយជាទីបំផុតថា.“ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថ ម្នាលភិក្ខុទាំងឡាយ, តថាគតសុំរំលឹកផ្ដែផ្ដាំអ្នកទាំងអស់គ្នា ក្នុងពេលជាទីបំផុតនេះម្ដងទៀតថា សង្ខារទាំងឡាយមិនទៀងទាត់ឋិតថេរទេ តែងតែវិនាសសូន្យសោះអស់ទៅជាធម្មតា, (ដោយហេតុនេះ) អ្នកទាំងឡាយចូរធ្វើប្រយោជន៍ឲ្យសម្រេចកុំគប្បីធ្វេសប្រហែសបណ្ដែតបណ្ដោយស្មារតីឡើយ!” ។ នេះហើយជាបច្ឆិមពុទ្ធវចនៈ គឺជាព្រះពុទ្ធឱវាទពៅបំផុត ។ ចាប់តាំងពីត្រឹមនោះមក ព្រះអង្គមិនមានព្រះពុទ្ធដីកាថាអ្វីទៀតឡើយ ទ្រង់ធ្វើបរិនិព្វានបរិកម្ម សោយបរមសុខតែម្ដង ។

ព្រោះហេតុនោះហើយបានជាអ្នកប្រាជ្ញខាងព្រះពុទ្ធសាសនាលោក លើកយកថ្ងៃ វិសាខបុណ្ណមីរាត្រីព្រះចន្ទ្រពេញវង់ប្រកបដោយ វិសាខនក្ខត្តឫក្ស ទុកជាអភិលក្ខិតកាល ដែលនិយមកំណត់ហៅថា "ថ្ងៃវិសាខបូជា" ជាថ្ងៃសំខាន់បំផុតក្នុងផ្លូវព្រះពុទ្ធសាសនា ព្រោះមាន ហេតុជាមហាស្ចារ្យកើតមានឡើងចំពោះព្រះបរមសាស្ដាសម្មាសម្ពុទ្ធបីលើក គឺ ទ្រង់ប្រសូត, បានត្រាស់ដឹងព្រមទាំងចូលព្រះបរមនិព្វាន តែក្នុងថ្ងៃខែដដែលៗនោះ, ទើបជាមហាករតិបីជាទីដាស់តឿនចិត្តពុទ្ធ-សាសនិកជនឲ្យរៀបចំចាត់ចែងគ្រឿងសក្ការបូជា ចំពោះព្រះរតនត្រ័យ ជាមហោឡារិកពិសេសប្លែកជាងថ្ងៃបូជាធម្មតា សូម្បីព្រះបរមមហា-ក្សត្រិយ៍ក៏ទ្រង់បានចាត់ ព្រះរាជបំរើឲ្យនាំយកគ្រឿងសក្ការៈទៅបូជា បំពេញព្រះរាជកុសលនៅនាវត្តធំៗ ក្នុងព្រះរាជធានីតាមព្រះរាជប្រវេណី ដែរ ទាំងខាងរាជរដ្ឋាភិបាលក៏បានលើកយកថ្ងៃវិសាខបូជានេះទុកជាថ្ងៃ បុណ្យដ៏សំខាន់ខាងផ្លូវរាជការ មានកំណត់សាពបរឲ្យឈប់ធ្វើការរៀង រាល់ឆ្នាំ ដើម្បីបើកឱកាសឲ្យអ្នករាជការបានទៅបំពេញបុណ្យកុសលតាម វត្តអារាមផ្សេងៗ ជាមួយនឹងប្រជាជន ដោតបង្ហូទង់ជាតិ - សាសនាអុជបំភ្លឺ ប្រទីបផ្កាលាបូជាព្រះត្រៃរ័ត្ន ក្នុងឋានៈដែលព្រះពុទ្ធសាសនាជាសាសនា របស់រដ្ឋ, ជាសាសនាប្រចាំជាតិខ្មែរ ។ នៅស្ថានវិទ្យុផ្សាយសម្លេង

កំមានធ្វើវិសាខបូជាសំដែងធម៌ទេសនា ប្រកាសពាក្យពិតដែល ព្រះ-សម្ពុទ្ធបរមគ្រូទ្រង់បានប្រៀនប្រដៅហើយក្នុងអតីតកាល ។ នៅតាមវត្តអារាមផ្សេងៗតែងមានការដើរប្រទក្សិណ ព្រោះថាការជាទីតម្កល់ព្រះពុទ្ធបដិមា និងទីលានចេតិយស្ថានជាដើម ហើយមានមហាធម្មស្សវនាអស់ពេលដ៏សមគួរ ជួនកាលដរាបដល់ព្រឹកភ្លឺស្វាងក៏មាន ។ នៅរាជធានីភ្នំពេញពិធីពិសាខបូជាឆ្នាំនេះ មានរសជាតិរស្មីត្រចះត្រចង់ប្លែកជាងសព្វឆ្នាំក្រៃលែងណាស់ ដោយមានកិត្តិយសដែលបានទទួលលោកមហាបណ្ឌិត គ.ប.មា"ល"ល:សេកេរ: ប្រធាននៃពុទ្ធិកសមាគមពិភពលោកមករួមធ្វើជាមួយផង ។

គួរយើងនឹករលឹកឡើងចាំក្នុងក្ដួចក្នុងចិត្តនោះ ចំពោះព្រះឧទានកថានិងព្រះសុត្តពេទ ដែលព្រះបរមគ្រូទ្រង់ត្រាស់ប្រទានទុកមកទាំងបីកន្លែងក្នុងថ្ងៃខែដែលមានឈ្មោះតែមួយផង ដូចបានរៀបរាប់មកខាងដើម ហើយគប្បីយកទុកជាគោលគតិនៃសេចក្ដីប្រតិបត្តិដើម្បីបានសេចក្ដីសុខ-ចំរើន ក្នុងឥធលោកនិងបរលោក ។

សូមអានុភាពនៃព្រះសិរីរតនត្រ័យ រីកសាយឲ្យទៅគ្រប់ទិសានុទិស បំពេញហិតានុហិតប្រយោជន៍និងសន្តិសុខចំពោះសត្វលោក អស់កាលយឺនយូរអង្វែង ។

ប. ស. ធម្មាភម

# ព្រះពុទ្ធសាសនាគឺអ្វី?

ប្រជាជននៅក្នុងប្រទេសដែលមិនធ្លាប់មានពុទ្ធសាសនាដូចជាប្រជាជនក្នុងប្រទេសនៅទ្វីបអឺរ៉ុបជាដើម មើលព្រះពុទ្ធសាសនាមិនយល់បានដោយងាយ ដូចប្រជាជនក្នុងប្រទេសដែលមានព្រះពុទ្ធសាសនាស្រាប់ទេ ព្រោះព្រះពុទ្ធសាសនាជាសាសនាហេតុផល លុះត្រាតែបានទទួលការសិក្សាបរិបូណ៌ ហើយប្រើប្រាជ្ញាពិចារណារាវរកហេតុផលបន្តិចម្តងៗ ទាល់តែជួបសេចក្តីច្បាស់ទើបដឹងរសជាតិស្គាល់ដម្លៃព្រះពុទ្ធសាសនា ៗ

ក្នុងពេលដែលសង្គ្រាមលោកទីពីរកន្លងបាត់ទៅហើយ សង្គ្រាមលោកទីបីក៏គំហឹមឡើងទៀត សម្លេងមុខគួរសែនស្ញុតប៉ិត្តឆោឡោអឹងកង លេចឮរន្ទឺឡើងគ្រប់ទិសទីក្នុងសកលលោកថា ទឹកមេត្តា គឺពុទ្ធសាសនា !!!

នេះជាសម្លេងលោកទាំងមូល លោកអាស៊ី លោកអឺរ៉ុប លោកអាមេរិក លោកអាហ្វ្រិក ដែលបានទៅកាន់ទីប្រជុំពុទ្ធសាសនាពិភពលោកនៅក្រុងកូឡាំបូប្រទេសស្រីលង្កាថ្មីៗនេះ ។ លោកទាំងមូលនេះ បានប៉ះទង្គិចដោយភ្លើងសង្គ្រាម គ្រាប់កាំភ្លើង គ្រាប់បែកដេះ គ្រាប់បែកផ្ទុះ គ្រាប់បែកបរមាណូ បានឃើញអំណាចភ្លើងសង្គ្រាមប្រាកដយ៉ាងនេះ ក៏កិតភ័យរន្ធត់តក់ស្លុតរអាខ្លាចភ្លើងសង្គ្រាមដូចជាគេខ្លាចភ្លើងនរក ហើយស្វះស្វែងរកទីពឹងដែលនាំឲ្យបានសេចក្តីសុខ ។ រឿងស្វែងរកព្រះពុទ្ធ-សាសនានេះមិនតែឥឡូវនេះទេ មានយូរយារណាស់ហើយ មានអ្នកខ្លះដឹង

កប៉ាល់កាត់ឆ្លងសមុទ្រ អ្នកខ្លះជិះអាកាសយានហោះហើរដើរលើអាកាស វេហាស៍ ឆ្លងពីទ្វីបមួយទៅទ្វីបមួយ អ្នកខ្លះទៀតខំស្វះពន្ទុះឡើងទៅកាន់កំពូលលោកគឺប្រទេសទីបេត៍ ដើម្បីទៅរកពុទ្ធសាសនា ហើយយកមកសរសេរចងជាសៀវភៅច្រើនបែបច្រើនយ៉ាង តាមទស្សនៈរៀងខ្លួន ដោយមានបំណងតែមួយ គឺបើកបង្ហាញលោកដែលភ័យដោយសង្គ្រាមឲ្យឃើញច្បាស់លាស់នូវពុទ្ធសាសនាដែលជាសរណៈក្សេមក្សាន្តទីពឹងជាសរណៈដ៏ឧត្តម ។ ក្នុងការជំនួយរកពន្លឺព្រះពុទ្ធសាសនានេះ ពួកអ្នកប្រាជ្ញខាងវិជ្ជាពុទ្ធសាសនាច្រើននាក់ បានខំសង្កេតពិនិត្យរាវរកសេចក្ដីពិតក្នុងព្រះពុទ្ធសាសនា រួមដៃជាមួយពួកអ្នកប្រាជ្ញខាងបុរាណវត្ថុដែលបានគាស់កកាយព្រះធរណីតាមទីឋានបុរាណ ស៊ើបរកភស្តុតាងយកមកលាតត្រដាងបង្ហាញលោក ។ ការរកឃើញទាំងប៉ុន្មានមានដម្លៃលើសគណនា តែអនិច្ចា ការរកឃើញទាំងនោះ មិនទាន់អាចបញ្ជាក់ខ្លឹមសារព្រះពុទ្ធសាសនា ឲ្យច្បាស់ប្រាកដដូចជាគេបើកបង្ហាញរបស់អ្វីមួយដែលគេគ្របឲ្យឃើញច្បាស់បានឡើយ ដូចលោកអង់ស្យាណុសរ-សេរក្នុងកថាមុខក្នុងពេលដែលលោកប្រែពីសៀវភៅលោកត្រឹមមកជាភាសាបារាំងថា: "ព្រះពុទ្ធសាសនាមានពន្លឺភ្លឺត្រចះអស់រយៈចំនួន ៥ សតវត្សរ៍ ក្រោយតមក ក៏ធ្លាក់ទៅនៅកណ្ដាលរាត្រីកាល ២.០០០ ឆ្នាំគឺលទ្ធិគ្រូបាអាចារ្យដ៏ធំធឹកធងធល់ដោយការតាំងនិកាយថ្មីៗ លុះដល់ខួបទ្រង់

ទ្រាយគេរមិលមើលមិនយល់ហើយ ទើបចាប់ផ្ដើមសើរើគាស់កកាយ បើកយកមកបង្ហាញ ថែមទាំងមានអ្នកធ្វើបេះដាំងព្រះសម្មាសម្ពុទ្ធទៅទៀត សរសេរសៀវភៅបញ្ចេញប្រាជ្ញច្រើនក្រៃលែង ច្រើនដល់ជាហួសខ្នាតមាត្រា ខ្លះថានេះ ខ្លះថានោះ ដូចអ្នកស្ទាបដំរី" ៗ ហេតុនេះការស្វែងរកព្រះពុទ្ធសាសនាតាមសភាពពុទ្ធសាសនា ដែលយើងមើលឃើញសព្វថ្ងៃនេះ សំដែងឲ្យឃើញថាគេមិនអាចនឹងស្គាល់បានដោយងាយ ៗ ដូចជាកូនស្គាល់មាតាបិតាទេ ព្រោះហេតុ ២ ប្រការគឺ: ៖

១ – ព្រះពុទ្ធសាសនាកើតនៅប្រទេសឥណ្ឌៀ យូរយារណាស់ប្រមាណជា ២៥សតវត្សរ៍មកហើយ កាលដែលផ្សាយចេញពីមាតុភូមិចូលទៅកាន់ប្រទេសតូចធំក្នុងសកលលោក ពុទ្ធសាសនាបែកចេញជានិកាយផ្សេង ៗ ហើយចូលទៅប្រទេសនានា ក៏លាយច្រឡំបល់ដោយលទ្ធិក្នុងប្រទេសនោះ ៗ ទៀត គឺក្លាយកេទយកពណ៌តាមភូមិប្រទេសប្រែទៅជាមិនបរិសុទ្ធ គេមើលមកឃើញមានពណ៌ស្រមឹកប្រហែលពណ៌សាសនាទាំងពួង ដូចទឹកថ្លាបរិសុទ្ធក្នុងប្រភពលើកំពូលភ្នំហិមពាន្ត កាលដែលហូរទៅតាមជ្រួសជ្រលងដងស្ទឹង កាត់ព្រៃព្រឹក្សា កាត់វាលស្រែចម្ការ ភូមិឋាន និគមជនបទ លាយច្រឡំដីជាតិទឹកដីមនុស្សសត្វក៏ក្លាយទៅជាល្អក់មិនបរិសុទ្ធ មានរសជាតិទៅផ្សេង ៗ តាមភូមិឋាននោះ ៗ បាត់រសជាតិដើម អ្នកត្រូវការរករសជាតិដើម មិនអាចនឹង

ត្រង់ញែករកធាតុដើមបានដោយងាយឡើយ ។ នៅប្រទេសដែលមាន ពុទ្ធសាសនា គេមើលឃើញមានការប្រែទ្យំបល់ច្រើនប្រការណាស់ ច្រើនហួសដល់ជាពណ៌នាលើទំព័រនេះពុំបាន ដូចហែសពមានលោក អភិធម្ម មានលោកមាតិកា មានលោកឈរចាំបង្សុកូលតាមថ្នល់ សូត្រធម៌រាយត្រដោកប៉ុកៗ ពាក់រូបភាគបំទមុខហើយដើរផ្តុំខ្ទយសូមទាន តថ្ងៃ ទៅសូត្រធម៌ស៊ីឈ្នួល ស្មៀកពាក់ជាតួកំបាក់ក្បាច់ក្នុងពិធីធ្វើបុណ្យ ទក្ខិសកុសល បុទ្ឡាម៉ាជាស្តេចគ្រប់គ្រងប្រទេសផង ជាសង្ឃនាយក ផង បែបសាសនាមហាម័ត ហើយតាំងខ្លួនជាអវតារព្រះពោធិសត្វ ចុះមកកើតក្នុងលោកយើងនេះ ដើម្បីប្រោសស្រង់សត្វ បែបដូចព្រះ យេស៊ូគ្រិស្តដូច្នេះជាដើម... ។ល។

២ — អ្នកនិពន្ធខាងព្រះពុទ្ធសាសនាច្រើននាក់ ដែលមិនមែន ជាពុទ្ធសាសនិក: មានខ្លះជាអ្នកកាន់សាសនាដទៃផង បេះដឹងព្រះពុទ្ធ-សាសនាតិចតួចស្តួចស្តើង ចាប់យកខ្លឹមសារព្រះពុទ្ធសាសនាមិនបាន សរសេរចងជាសៀវភៅរកប់ពាន់បោះពុម្ពផ្សាយជាវិជ្ជាអាជីព ដើម្បីយក កំរៃចិញ្ចឹមជីវិត ត្រូវខ្លះ ខុសខ្លះ ដូចមនុស្សខ្វាក់គតអ្នកដឹកដៃដើរទៅ ពានលើផ្លូវខ្លះ ខុសផ្លូវខ្លះ ។

ការលាយឡំទាំង ២ ប្រការដូចរៀបរាប់មកខាងលើនេះ សុទ្ធសឹង ជាសទ្ធម្មប្បដិរូប ជាកុំធំ ៗ បំទមុខព្រះពុទ្ធសាសនា នាំបន្ថោកបន្ទាប

ផង នាំឲ្យគេកន្ត័ប្រទាំងផង ៗ លទ្ធផលកើតពីការកន្ត័ប្រទាំងមិនដឹងមុខ ដឹងបាទនេះ ធ្វើឲ្យគេទាយព្រះពុទ្ធសាសនាខុស ឲ្យគេវាយតម្លៃព្រះពុទ្ធសាសនាថាដូចជាសាសនាទាំងពួង ៗ

មួយទៀត ព្រះពុទ្ធសាសនាមានអត្តគម្ពីរភាពក្នុងខ្លួនស្រាប់ ហើយផ្ទុយនឹងទស្សនៈនៃសត្វលោក ដែលមានក្តែកប្រកបដោយធូលីពោលគឺ រាគៈទោសៈ មោហៈផង ៗ អត្តគម្ពីរភាពនៃពុទ្ធសាសនានេះ លុះត្រាតែបុគ្គលណាប្រាសចាករាគៈ ទោស មោហៈ មានការសិក្សាបរិបូណ៌ ហើយពិចារណាម៉ត់ចត់ ទើបចាក់ធ្លុះយល់សេចក្តីច្បាស់លាស់បាន ស្ដូម្បីព្រះសម្មាសម្ពុទ្ធ កាលទ្រង់ទើបនឹងបានត្រាស់ដឹងធម៌ថ្មីៗ ក៏ទ្រង់ឈ្វេងយល់ថា ធម៌ដែលព្រះអង្គរកឃើញ ផ្ទុយគ្នានឹងទស្សនៈនៃសត្វលោកទៅហើយ ចាំបាច់និយាយថ្វី ចំពោះសាមញ្ញជនដូចយើងរាល់គ្នានេះ បានជាទ្រង់តាំងព្រះទ័យជាអប្បោស្សុកភាព មិននាំពាក្យការសំដែងធម៌ប្រោសវេនេយ្យសត្វ ដូចព្រះតម្រាស់ដែលទ្រង់ត្រាស់ទុកថា: —

"ណ្ហើយបុះ ! តថាគតមិនគួរនឹងសម្តែងធម៌ ដែលតថាគតបានត្រាស់ដឹងហើយដោយសេចក្តីលំបាកនេះទេ សត្វទាំងឡាយដែលមានរាគៈទោសៈមោហៈគ្របសង្កត់ហើយ មិនងាយនឹងត្រាស់ដឹងនូវធម៌នោះបានទេ សត្វទាំងឡាយដែលកំពុងត្រេកអរដោយរាគៈ ដែលគំនរងងឹត

គឺអវិជ្ជាកំពុងរួបរឹត មិនឃើញនូវធម៌ដែលនាំឲ្យពួកសត្វដល់នូវព្រះនិព្វាន ជាធម៌ល្អិតសុខុមជ្រាលជ្រៅ ដែលសត្វឃើញបានដោយកម្រនោះបាន ទេ ៕ ។

ព្រះពុទ្ធសាសនា តាមទស្សនៈសកលលោកដែលមិនមែនជាពុទ្ធសាសនិក អ្នកខ្លះថាសំរាលចេញមកពីសាសនាព្រាហ្មណ៍ ព្រោះក្នុងផ្លូវព្រះពុទ្ធសាសនាមានធម៌អាចិក្នុងសាសនាព្រាហ្មណ៍ច្រើន, ខ្លះថាជាសីលធម៌ (Moralité) ដូចជាលទ្ធិអ្នកប្រាជ្ញខុងជឺ, អ្នកខ្លះថាជាវិទ្យាសាស្ត្រឬទស្សនវិជ្ជា (Science ou Philosophie) ដូចលទ្ធិអ្នកប្រាជ្ញប្លាតុងឬអារិស្តូត (Platon ou Aristote) ។ គេចេះតែថា, ថានេះថានោះ រកពិតប្រាកដមិនឃើញ ស្រេចហើយតែគេមើលឃើញ ។ ចុះបើក្នុងពេលដែលលោកកំពុងនៅក្នុងងងឹតងងល់ មើលព្រះពុទ្ធសាសនាមិនយល់នេះ មានអស់លោកអ្នកប្រាជ្ញច្រើននាក់ ដែលមានប្រទីបពោលគឺប្រាជ្ញាមុះមុត យកមកអុចទ្រោលបំភ្លឺមើលយល់ព្រះពុទ្ធសាសនាច្បាស់ ។ បណ្ដាអ្នកប្រាជ្ញទាំងឡាយនោះ យើងគួរស្ញើចដល់ទស្សន លោករីសដាវិដ (RysDavids) ។ លោកនេះជាអ្នកចេះដឹងវិជ្ជាបុត្តាប្រទេសយ៉ាងជ្រៅឆ្ងាយទូលាយ ជាអ្នកពេញចិត្តរិះរកលទ្ធិសាសនាផ្សេងៗក្នុងលោក ត្រូវជនអង់គ្លេសដែលជាជនរួមជាតិជាមួយនឹងលោក ពោលពាក្យទ្រគោះបោកបោះបន្តុះបង្អាប់ចំពោះមុខថា លោកជាជនអង់គ្លេស ដែលជាម្ចាស់ពិភពលោក មិនគួរប្រកាសជាពុទ្ធ-

សាសនាទិកដែលជារបស់ជនអាស៊ីកាន់នោះ ។ លោកវេសជាវិឆ្លើយ យ៉ាងញញឹមដោយចិត្តត្រជាក់ថា: "ការជាពុទ្ធសាសនិកឬទេនោះ មិនជាសំខាន់អ្វីទេ រឿងសំខាន់នោះគឺថា ខ្ញុំបានសិក្សាពិនិត្យមើលពាក្យប្រៀនប្រដៅនៃសាសនាសាកលលោកហើយ ក្នុងពាក្យប្រៀនប្រដៅទាំងអស់នោះ ខ្ញុំមិនឃើញថាមានអ្វីល្អនិងខ្លឹមសារក្រៃលែងជាងមគ្គប្រកបដោយអង្គ ៨ ប្រការរបស់ព្រះសម្មាសម្ពុទ្ធទេ ដូច្នោះទើបខ្ញុំពេញចិត្តគ្រប់គ្រងជីវិតតាមវិធីនៃមគ្គនោះ" ។ តាំងពីកាលព្រះពុទ្ធសាសនាផ្សាយចូលទៅកាន់ទ្វីបអឺរ៉ុបមកដល់បច្ចុប្បន្នកាលនេះ ប្រជាជនអឺរ៉ុបដែលទទួលពន្លឺថ្មីនេះ បានក្រេបផឹករសជាតិព្រះពុទ្ធសាសនា ក៏ប្រែចិត្តគំនិតច្រើននាក់ ហើយប្រកាសខ្លួនថាជាអ្នកកាន់ព្រះពុទ្ធសាសនា ។ ពុទ្ធសាសនិកជនពួកនេះ ជាអ្នកប្រកាសពុទ្ធសាសនា តាំងខំប្រឹងសរសេរសៀវភៅឬទស្សនាវដ្ដីគ្រប់ភាសារៀងខ្លួនផ្សាយព្រះពុទ្ធសាសនា ហើយប្រកាសប្រាប់ឲ្យមើលតែសៀវភៅណាដែលសរសេរដោយដៃអ្នកកាន់ពុទ្ធសាសនា ។ លោក ហាំហ្វ្រយស៍ (Ch. Humphreys) ជាអធិបតីសមាគមពុទ្ធសាសនានៅក្រុងឡុងប្រទេសអង់គ្លេស បានធ្វើដំណើរចេញពីប្រទេសអង់គ្លេសទៅដល់ប្រទេសជប៉ុនថ្មី ៗ នេះ ហើយសរសេរជាសៀវភៅមួយនិយាយពីគោលព្រះពុទ្ធសាសនា ថាមាន ១២ ប្រការ ។ អ្នកស្រីកញ្ញាលនស្បើ . អធិបតីនីសមាគមពុទ្ធសាសនាក្រុងបារីស៍សរសេរ

សៀវភៅទស្សនាវដ្ដី ផ្សាយព្រះពុទ្ធសាសនា ពន្យល់ឲ្យស្គាល់ព្រះពុទ្ធសាសនាពិត ៗ អ្នកស្រីកញ្ញានេះ កាលបើយើងបានឃើញស្នាដៃគេហើយ យើងនឹងយល់ថាជាអ្នកប្រាជ្ញពិត ៗ

ដូច្នេះ ព្រះពុទ្ធសាសនាមិនមែនសំកលចេញមកពីសាសនាព្រាហ្មណ៍ ថ្វីបើពុទ្ធសាសនាមានគោលខ្លះស្របនៅលើសាសនាព្រាហ្មណ៍ ព្រោះពុទ្ធសាសនាមិនបដិសេធសច្ចធម៌ គឺបើអ្នកណាមួយនិយាយសមទៅតាមហេតុផល សមតាមគន្លងធម៌ ព្រះពុទ្ធទ្រង់ក៏ប់រង់ថាត្រឹមត្រូវ ៗ ដែលនិយាយថា ព្រះពុទ្ធសាសនាមិនមែនកើតចេញមកពីសាសនាព្រាហ្មណ៍នោះ ព្រោះពុទ្ធសាសនានឹងសាសនាព្រាហ្មណ៍ មានចំណុចសំខាន់ធំខុសគ្នាស្រឡះ ពុទ្ធសាសនាជាធម្មវាទី សាសនាព្រាហ្មណ៍ជាលទ្ធិ ៗ សាសនាព្រាហ្មណ៍មានទេវតា ៣ ជាអាទិទេព គឺព្រះព្រហ្ម ព្រះឥសូរនឹងព្រះនារាយណ៍ អវតារទៅមកក្នុងត្រៃភព ជាមានបរមាត្មន៍បិតថេរថេរកាលនៅជានិច្ច ជាអាត្មន៍នៃសាវកអ្នកប្រតិបត្តិតាមនឹងរលាយក្លាយទៅជាបរមាត្មន៍តែមួយ រួមនឹងបរមាត្មន៍នៃព្រះអាទិទេព, ជាមានពិធីសុតិសូត្របួងសួងសូមសេចក្ដីសុខពីព្រះអាទិទេពដែលជាម្ចាស់សេចក្ដីសុខ, ជាមានសក្តិទុកដូចជាជាយា ជាអ្នកបរិភោគកាម ចេះលោភចេះក្រេវក្រោធ ដូចសាមញ្ញជន ៗ ឯព្រះពុទ្ធសាសនា ព្រះពុទ្ធមិនមែនជាអាទិទេព ទ្រង់ជាមនុស្សលោកដូចយើង ទ្រង់មិនប្រែកបដោយ

កិលេសទេ ជាធម៌ទាំងពួងជាអនត្តា សាវកអ្នកប្រតិបត្តិតាមនឹងឃើញធម៌ ដូចព្រះអង្គ ថាទ្រង់មិនមែនជាម្ចាស់សេចក្ដីសុខ សេចក្ដីសុខបានដោយខ្លួនឯង អ្នកណាធ្វើអ្នកនោះបាន សេចក្ដីល្អអាក្រក់កើតចំពោះខ្លួនឯង អ្នកណាធ្វើអាក្រក់បានអាក្រក់ អ្នកណាធ្វើល្អបានល្អ ។

ព្រះពុទ្ធសាសនា មិនមែនជាសីលធម៌យកល្អក្នុងលោកនេះដូចអ្នកប្រាជ្ញខ្លះជឿនោះទេ ព្រោះសីលធម៌ខ្លះជឿ ដឹកនាំឲ្យបុគ្គលបានសេចក្ដីសុខតែនាលោកិយនេះ មិនអាចដឹកនាំឲ្យបានសេចក្ដីសុខចំរើនក្នុងលោកនេះផង ហើយនឹងដឹកនាំឲ្យបានបរមសុខផងដូចព្រះពុទ្ធសាសនាទេ ។ មួយទៀត ខ្លះជឿគ្រាន់តែជាអ្នកប្រាជ្ញខាងសីលធម៌ នៅប្រកបដោយលោភៈ ទោសៈ និងមោហៈ ។

ព្រះពុទ្ធសាសនាមិនមែនជារីលីស្យុង (Religion) ដូចសាសនាគ្រិស្ត ។ រីលីស្យុងមកពីពាក្យឡាតាំងថា (Religio) ប្រែថា "ជាប់ទាក់ទង" ជាប់ទាក់ទងសត្វលោកនឹងព្រះអាទិទេព ដោយពិធីសូត្រស្មូតបួងសួងបន់ស្រន់សូមសេចក្ដីសុខគឺសូត្រអង្វរសូមឲ្យព្រះអាទិទេពប្រទានសេចក្ដីសុខឲ្យ ព្រោះព្រះអាទិទេពជាម្ចាស់សេចក្ដីសុខដូចសាសនាព្រាហ្មណ៍ បានជាមានពាក្យបារាំងថា (Prière) ពាក្យនេះមកពី ('rier) ថា "សូមអង្វរ បន់" ប្រែថា "សូត្រធម៌" ឬថាធម៌មិនត្រូវទេ ។ អាទិទេពក្នុងសាសនាគ្រិស្តនេះមាន ៣ គឺព្រះស៊េហូវ៉ាស៍ (Jehovas) ជាព្រះបិតា ១

ញាណបរិសុទ្ធ (Saint-Esprit) ១ ព្រះយេស៊ូគ្រិស្ត (Jesus-Christ) ជាព្រះបុត្រ ១ ។ ក្នុងលទ្ធិគ្រិស្ត សាវកត្រូវប្រគល់ជំនឿដាច់ខាតទៅព្រះអាទិទេព មិនមានផ្លូវតវ៉ា មិនបាច់តាំងជាប្រស្នាសួរដេញដោលរកហេតុផលថាដូចម្តេចក៏ត្រូវជឿទេ ត្រូវតែជឿតាមព្រះអាទិទេពមានទេវឱង្ការបង្គាប់ ។ បើដូច្នេះ ពាក្យថា រលីស្យុង មិនគួរយកទៅប្រើហៅពុទ្ធសាសនាទេ ព្រោះនឹងនាំឲ្យគេកត់ យល់សេចក្តីខុសថាពុទ្ធ-សាសនាដូចលទ្ធិគ្រិស្តដែរ ហៅបានតែលទ្ធិសេយ្យសាសន៍ ក្រៅពុទ្ធសាសនាដូច ព្រាហ្មណ៍ គ្រិស្ត ឥស្លាម (មហាម័ត) នឹងលទ្ធិខ្មោចបីសាច អារក្សទេព្រក្សជាដើម ។ ក្នុងពុទ្ធសាសនា ព្រះពុទ្ធទ្រង់ប្រទានសេរីភាពក្នុងសទ្ធា ទ្រង់មិនបង្ខំឲ្យអ្នកណាជឿព្រះអង្គទេ តែទ្រង់សំដែងឲ្យជឿដោយមានហេតុផលជាគោល ហើយប្រកបដោយប្រាជ្ញផង គឺសទ្ធានឹងបញ្ញា ដោយទ្រង់យល់ថា បើប្រើសទ្ធាដែលហួសពេកច្រើនជាងបញ្ញានឹងទៅជាល្ងង់ បើប្រើបញ្ញាដែលហួសពេកខ្លាំងជាងសទ្ធានឹងទៅជាយល់សេចក្តីខុស ត្រង់នេះ បើចង់ឲ្យទ្រនិបត្រាជ្ញតាំងនៅក្នុងតុល្យភាពត្រឹមត្រូវតាមគន្លងធម៌ ត្រូវប្រើសទ្ធានឹងបញ្ញាឲ្យប្រព្រឹត្តទៅដោយកម្លាំងស្មើគ្នា ។

ព្រះពុទ្ធសាសនា មិនមែនជាវិទ្យាសាស្ត្រនឹងទស្សនវិជ្ជាទេ ។ វិទ្យា-សាស្ត្រ គ្រាន់តែជាបតិដ្ឋកម្មឲ្យកើតជាវត្ថុ ឯទស្សនវិជ្ជា គ្រាន់តែជាសម្មតិ-

ឃ្លានខាងផ្លូវគំនិត ៗ វិទ្យាសាស្ត្រនិងទស្សនវិជ្ជានៃលោកបច្ចុប្បន្ននេះ ប្រកបដោយហេតុផលសាកលលោកនិយម តែបើទុកជាដូច្នោះ ក៏តស៊ូនឹងស្វាក្ខាតធម៌មិនបាន ដូចអ្នកវិទ្យាសាស្ត្របានប្រតិស្ឋឲ្យកើតមានវិទ្យុ អគ្គិ-សនី រថយន្ត អាកាសយាន ទូរស័ព្ទ ទូរលេខ ឯអ្នកទស្សនវិជ្ជា ប្រើការគិតវិចិត្រពិស្ដារ កាលបើយើងពិចារណាឲ្យល្អិតល្អហើយ យើងនឹងឃើញថា អ្នកវិទ្យាសាស្ត្របានគ្រាន់តែទទួលការស្រណុកស្រួលក្នុងការគ្រប់គ្រងជីវិត ឬបើពោលខ្លីៗ ក៏គឺប្រយោជន៍បំពោះមុខ ឯអ្នកទស្សនវិជ្ជា បានគ្រាន់តែប្រើកម្លាំងការគិតឲ្យវិសេសជាងអ្នកវិទ្យាសាស្ត្រប៉ុណ្ណោះ ៗ ឧបមាថា យើងឃើញសន្ទឹកឈើមួយសន្ទឹក អ្នកវិទ្យាសាស្ត្រនិយាយថាយើងឃើញបានតែពណ៌សន្ទឹកឈើទេ បើសន្ទឹកឈើមិនមានពណ៌ ឬនៅក្នុងទីងងឹត យើងក៏មើលមិនឃើញ ៗ ឯពណ៌ដែលយើងមើលឃើញខុសគ្នានេះ មកពីធាតុប្រកបបរមាណូមួយៗ គឺប្រូតុងអេឡិកត្រុង នឹង នឺត្រុង មានតិចច្រើនជាងគ្នា ៗ បើមានអ្នកទស្សនវិជ្ជាម្នាក់អង្គុយនៅជិតយើងផង គេនឹងដេញដោលតទៅទៀតថា ពណ៌នេះគឺអ្វី? ពណ៌មានពិតឬមិនមែន? ពុំនោះ អ្នកវិទ្យាសាស្ត្រ គន់គិតរកត្រឹមតែជីវិតបច្ចុប្បន្ននឹងទីបំផុតត្រឹមស្លាប់ ឯអ្នកទស្សនវិជ្ជាគន់គិតតទៅទៀតថា ស្លាប់ហើយទៅឯណា? កើតទៀតឬទេ? ព្រោះទស្សនវិជ្ជាមានការសង្ស័យជាប្រកត ត្រូវសង្ស័យហើយលើកជាប្រស្នាសួរហេតុដល់ទីបំផុត ឬហេតុដល់តបមិនកើតក៏មាន មួយទៀត

បេអ្នកវិទ្យាសាស្ត្រលើកលែងតែ ព្រោះខ្ពស់ហួសវិស័យដែលនឹងធ្វើពិសោធន៍បាន អ្នកទស្សនវិជ្ជាក៏រើសយកមកតាំងជាប្រស្នាដេញដោលរកហេតុផលតទៅទៀត ហេតុនោះអ្នកវិទ្យាសាស្ត្រជាន់ខ្ពស់ក៏ក្លាយទៅជាទស្សនវិជ្ជាតទៅមួយជាន់ទៀត តែការគិតអ្នកទស្សនៈវិជ្ជានេះនៅគង់វង់ហេតុផល គឺត្រូវអាស្រ័យការដៅដោយតក្កវិទ្យា (logique) ព្រោះហេតុដូច្នោះ អ្វីដែលខ្ពស់ហួសវិស័យវិទ្យាសាស្ត្រត្រូវប្រគល់ឲ្យទៅទស្សនវិជ្ជា តែឯការខ្ពង់ខ្ពស់ខាងទស្សនវិជ្ជានេះ នៅទើត្រឹមការដៅ ការដៅនេះ ខាងព្រះពុទ្ធសាសនាមិនប្រកាន់ជាល័ក្ខហានទេ ដូចតក្កហេតុដែលព្រះពុទ្ធសំដែងទុកក្នុងកាឡាមសូត្រ ។ ព្រះពុទ្ធទ្រង់ប្រៀនប្រដៅតាមដែលទ្រង់ត្រាស់ដឹងប្រត្យក្ស មិនមែនដៅដូចអ្នកទស្សនវិជ្ជាទេ ហេតុដូច្នេះទើបឃើញថាព្រះពុទ្ធសាសនា ខ្ពស់ហួសទស្សនវិជ្ជាតទៅទៀត ព្រោះអ្នកទស្សនវិជ្ជា បានត្រឹមតែការគិតរកហេតុផលហើយដៅប៉ុណ្ណោះ ឯព្រះពុទ្ធសាសនាចុះដៃប្រតិបត្តិរហូតដល់ទៅរកឃើញសេចក្ដីពិតដោយខ្លួនឯង ។ អ្នកវិទ្យាសាស្ត្រត្រូវរកតទៅទៀត ការរកឃើញខ្លះនេះក៏ឃើញក្រោយ ព្រះសម្មាសម្ពុទ្ធរកឃើញមក ២៥០០ ឆ្នាំហើយ ។ មួយទៀតអ្នកទស្សនវិជ្ជាជាសាមញ្ញជន នៅប្រព្រឹត្តផឹកស៊ុក ឫស្សាច្រណែនបែនទា ប្រកបដោយកិលេសទាំងឡាយ ធ្វើបំបាំងគាប់ចាក់គ្នា បានគ្រាន់តែជាអ្នកប្រាជ្ញគិតទៅតាមហេតុផល ហើយ

ទឹងមិនព្រមវៀចវេរជឿអ្វីដែលឥតហេតុផលប៉ុណ្ណោះ ឯព្រះអរហន្តាខីណាស្រពក្នុងព្រះពុទ្ធសាសនាមានព្រះសម្មាសម្ពុទ្ធជាដើម ចុះដៃប្រតិបត្តិដោយព្រះអង្គឯង រកសេចក្ដីពិតដ៏ប្រសើរឃើញប្រចក្សព្រះអង្គឯង គឺអរិយសច្ច ៤ ប្រការ ហើយជាអ្នកបរិសុទ្ធចាកកិលេសមន្ទិលសៅហ្មង ដូច្នេះព្រះពុទ្ធសាសនាប្រសើរវិសេសជាងវិទ្យាសាស្ត្រ ទឹងទស្សនវិជ្ជា ឥតតតាំបានឡើយ ។

ព្រះពុទ្ធសាសនា ជាសាសនាប្រកបដោយមេត្តាធម៌ ទឹងហៅថាមេត្តាសាសនាក៏គួរ ព្រោះនៅលើទំព័រព្រះត្រៃបិដកគ្រប់ទំព័រ សុទ្ធសឹងតែពេញដោយធម៌ដែលពន្យល់ឲ្យសត្វលោករួចពីសេចក្ដីទុក្ខ ។ មេត្តាធម៌នេះ មានគុណានុភាពខ្ពង់ខ្ពស់ណាស់ទឹងពណ៌នាឲ្យចប់ពុំបានទេ ។ ព្រះសុវណ្ណសាមពោធិសត្វ ដែលត្រូវព្រួញស្ដេចព្រានព្រៃបាញ់ រួចពីគ្រោះអន្តរាយ បានមានជីវិតឡើងវិញ ក៏ព្រោះតែមេត្តាធម៌ ។ ព្រះនាងសាមាវតី ដែលព្រះបាទឧទេនជាព្រះរាជស្វាមីចាញ់កលព្រះនាងមាគន្ទិយា បាញ់ព្រះនាងជាមួយរាជបរិវារ ៥០០នាក់ ហើយបានសេចក្ដីសុខក៏ព្រោះតែមេត្តាធម៌ ទាល់តែព្រះបាទឧទេនទ្រង់ដាក់ព្រះអង្គចុះលើកទសករប្រណម្យលាន់ព្រះឱស្ឋ មានបន្ទូលដោយអស្ចារ្យថា "សរនេះ ឥតមានវិញ្ញាណសោះ តែចេះដឹងគុណ មិនហ៊ានទៅមុតប្រហារជីវិតព្រះនាង ចុះអាត្មាអញនេះជាមនុស្សត្រឡាំង ម្ដេចក៏មិន

ដឹងគុណព្រះនាង" ។ មាឃមាណព បានរួចពីទុក្ខដែលគាមភោជកចោទថាក្បត់ផែនដី ហើយបានទៅជាព្រះឥន្ទ្រាធិរាជក៏ព្រោះតែធម៌មេត្តា ។ ព្រះសម្មាសម្ពុទ្ធ ផ្ចាញ់ដំរីនាឡាគិរីដែលទេវទត្តបង្អក់ស្រា ហើយលែងទៅឲ្យព្រេចព្រះអង្គ ក៏ដោយសារមេត្តាធម៌ជាទឹកអប់នេះដែរ ។ ហេតុនេះ បើលោកតាំងមូលមើលឃើញកម្លាំងអានុភាពមេត្តាធម៌ហើយតាំងចិត្តផ្សាយមេត្តាឲ្យបានគ្រប់គ្នា និយាយថ្វីសព្វបើទុក្ខបន្តិចបន្តួច សូម្បីលោកតាំងមូលដែលឆេះសន្ធោសន្ធៅដោយមហាសង្គ្រាមប្រល័យកល្ប ក៏អាចលត់ដោយទឹកអប់ពោលគឺមេត្តានេះបានដោយងាយ ៗ ។

ព្រះពុទ្ធសាសនា ជាសាសនាហេតុផល ជាសាសនាប្រាប់ផ្លូវថា នេះល្អ នេះអាក្រក់ នេះគុណ នេះទោស នេះផ្លូវទៅឋាននរក នេះផ្លូវទៅឋានសួគ៌ នេះផ្លូវទៅព្រះនិព្វាន ។ ព្រះពុទ្ធទ្រង់ត្រាស់ដោយព្រះអង្គថា "តថាគតគ្រាន់តែជាអ្នកប្រាប់ទេ" អ្នកណាធ្វើល្អបានល្អ អ្នកណាធ្វើអាក្រក់បានអាក្រក់ ល្អអាក្រក់កើតចំពោះខ្លួនឯង ឥតអ្នកណាឲ្យ ឥតអ្នកណាចាំទទួលជំនួស ហេតុនេះព្រះពុទ្ធសាសនា មិនមែនជាពិធីបួងសួង គឺសាសនាប្រាប់ផ្លូវ ។

ព្រះពុទ្ធសាសនា ជាអរិយសច្ចធម៌ សេចក្ដីពិតដ៏ប្រសើរ ទឹងថាជាលទ្ធិជាប់តពីសាសនាណា ឬអាចារ្យណាក៏មិនមែន ដូចមានសេចក្ដីបញ្ជាក់ក្នុងកាលាមសូត្រស្រាប់ ព្រះពុទ្ធសាសនា គឺពុទ្ធសាសនា ។

ខ្ញុំបានប្រស្រ័យជាមួយលោកអ្នកអានមកអស់កាលយូរហើយ អស់លោកអ្នកអានទំនងជាមានគំនិតគិតឃើញថា មិនឃើញពុទ្ធសាសនា ឃើញតែលទ្ធិផ្សេងៗ ដូច្នេះហ្ន៎? កុំអាលប្រញាប់ពេក! ព្រះពុទ្ធសាសនាគេមិនអាចមើលយល់ងាយៗឡើយ ខ្ញុំពណ៌នានេះបានតែមួយជ្រុងតូចទេ បានជាខ្ញុំនាំអស់លោកអ្នកអានដើរទៅមើលគំនិតលោកទាំងមូល ដែលគេតាំងជាចំណោទចោទចំពោះព្រះពុទ្ធសាសនាឲ្យផ្ដាប់សេចក្ដីមុនខ្លះសិន សិមនិយាយពីពុទ្ធសាសនាតាមទស្សនៈអ្នកកាន់ពុទ្ធសាសនា ។

ពាក្យដែលនិយាយរត់មាត់គ្រប់គ្នាថាពុទ្ធសាសនាៗ នេះ ជួនកាលលោកហៅថា ធម៌ផង វិន័យផង -ឬធម៌វិន័យត្រង់ក៏បាន ដូចសេចក្ដីប្រាកដនៅក្នុងមហាបរិនិព្វានសូត្រថា: "ម្នាលអានន្ទ! ធម៌ក្ដី វិន័យក្ដី អំណើះតតអំពីតថាគតទៅ នឹងជាគ្រូបាអាចារ្យប្រដៅអ្នក"; ជួនកាលលោកហៅថាពុទ្ធសាសនា ដូចក្នុងឱវាទបាដិមោក្ខថា: "កុំធ្វើបាប, ធ្វើកុសល ធ្វើចិត្តឲ្យផូរផង់ ពាក្យ ៣ ម៉ាត់នេះជាពុទ្ធសាសនា" ។

ពុទ្ធសាសនា ប្រែថាពាក្យប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ។ ចុះអ្វីហៅព្រះសម្មាសម្ពុទ្ធ? មានអ្នកកាន់ពុទ្ធសាសនាពួកខ្លះនិយាយថា ព្រះសម្មា-សម្ពុទ្ធជាសម្មតិនាម គឺជាឈ្មោះដែលគេសន្មតហៅ មិនមានរូបបុគ្គលប្រាកដទេ ខ្លះថាជាអាទិពុទ្ធ ថាជានេះជានោះ តាមសេចក្ដីយល់ឃើញតែរៀងខ្លួន តែសេចក្ដីពិត ព្រះសម្មាសម្ពុទ្ធ មិនមែនជាទេពតាព្រះឥន្ទ្រព្រះ

ព្រហ្មជាអាទិព្វ ឬគ្រាន់តែជារឿងព្រេងឥតឫសគល់ប្រាកដនោះទេ ព្រះសម្មាសម្ពុទ្ធជាអង្គមនុស្សពិតៗ គឺទ្រង់ជាមនុស្សឧប្បត្តិឡើងក្នុងលោកមនុស្ស, ដើរលើដីយើងនេះ មានមាតាបិតា មិនមែនដូចព្រះគ្រិស្តកើតពីស្រីក្រមុំឥតប្តីនោះទេ មានជីវប្រវត្តិប្រាកដ អ្នកប្រាជ្ញបុរាណវត្ថុដែលគាស់កកាយព្រះធរណីបានបញ្ជាក់ថាមានភស្តុតាងប្រាកដលាំងៗ ឥតនរណាប្រកែកបានឡើយ ។

ប្រមាណជា ២៤៩៤ ឆ្នាំមកហើយ មានមហាបុរសម្នាក់កើតឡើងក្នុងលោកនេះ ។ ព្រះបាទសិរីសុទ្ធោទនៈជាព្រះវរបិតា ព្រះនាងសិរី-មហាមាយាជាព្រះវរមាតា ទ្រង់ជាខត្តិយសក្យត្រកូល សោយរាជ-សម្បត្តិគ្រប់គ្រងសក្កជនបទ មានក្រុងកបិលពស្តុជាព្រះរាជធានី ។ មហា-បុរសនេះ កាលនៅជារាជកុមារមិនទាន់បានត្រាស់ដឹង មិនទាន់បានឈ្មោះជាសម្មាសម្ពុទ្ធទេ ទ្រង់ព្រះនាមថា សិទ្ធត្ថរាជកុមារ ប្រសូតនៅនាក្រោមដើមសាលព្រឹក្សក្នុងសួនលុម្ពិនី ជាទីឋានមួយនៅក្រៅព្រះនគរទិសពាយព្យនេបាលរដ្ឋ ប្រទេសឥណ្ឌាប៉ែកខាងជើង នៅថ្ងៃបុណ្ណមីខែពិសាខ មុនពុទ្ធសករាជ ៨០ ឆ្នាំ ។ កាលប្រសូតនោះ មានកើតអស្ចារ្យប្លែក ១ ឯព្រះបរមរូបក៏ប្រកបដោយមហាបុរសលក្ខណៈ ទឹងអសីត្យានុ-ព្យញ្ជនៈ ឥតមានរូបរាជកុមារអង្គណាប្រាកដស្មើបាន ពួកព្រាហ្មណ៍ជាអ្នកស្ទាត់ជំនាញហោរាសាស្ត្រ បានឃើញលក្ខណៈដូច្នោះក៏ទំនាយ

ថ្វាយថា ព្រះរាជកុមារអង្គនេះ នឹងបានជាស្តេចចក្រពត្រាធិរាជ បើស្តេចនៅគ្រប់គ្រងប្រទេស នឹងបានជាសាស្តាឯកប្រដៅសត្វលោក បើស្តេចលះបង់រាជសម្បត្តិចេញសាងមហាភិនិស្ក្រម ។ ព្រះបាទសិរីសុទ្ធោទនៈ កាលទ្រង់ព្រះសណ្តាប់ពាក្យព្យាករណ៍ដូច្នេះហើយ មានព្រះទ័យប្រាថ្នាឲ្យព្រះរាជបុត្រនៅគ្រប់គ្រងរាជសម្បត្តិ មិនពេញព្រះទ័យឲ្យចេញសាងអភិនិស្ក្រម ទើបព្យាយាមឲ្យព្រះរាជបុត្រត្រេកត្រេនក្នុងកាមផ្សេង ៗ ទ្រង់បានចាត់ឲ្យជាងកសាងឧទ្យានជាទីក្សាន្តមានស្រះ ៣ ដាំសុទ្ធតែឈូកមានពណ៌ផ្សេង ៗ គ្នា គ្រឿងឧបភោគ គ្រឿងបរិភោគ និងសេវកា-មាត្យបំរើ សុទ្ធតែល្អមានរបៀបរៀបរយ ទ្រង់ហាមប្រាមយ៉ាងដាច់ខាតមិនឲ្យឃើញសេចក្តីទុក្ខលំបាករបស់មនុស្សសោះ ដើម្បីកុំឲ្យព្រះរាជបុត្ររកផ្លូវចេញទៅបួសបាន ៗ មិនតែប៉ុណ្ណោះ ទ្រង់បានចាត់-គ្រូវិស្វមិត្រឲ្យបង្រៀនលទ្ធិសម័យ ចំណេះវិជ្ជាគ្រប់មុខមានអក្សរសាស្ត្រជាដើម ព្រមទាំងត្រៃវេទផង រហូតដល់ព្រះរាជបុត្រមានការសិក្សាជ្រៅឆ្ងាយទូលាយ ល្បីព្រះនាមថាមានព្រះប្រាជ្ញាលើសលែងកុមារជាសិស្សទាំងឡាយថែមទៀត ។

កាលព្រះជន្មបាន១៦ព្រះវស្សា ព្រះវរបិតាបានរៀបមង្គលាភិសេកជាមួយនឹងព្រះនាងពិម្ពាយសោធរា បានសាងប្រាសាទ ៣ ខ្នង សម្រាប់ប្រថាប់ក្នុងរដូវទាំង ៣ សុទ្ធតែប្រដាប់តុបតែងដោយគ្រឿងវិសេស

ហើយទ្រង់ហាមមិនឲ្យមនុស្សក្រីក្រ មនុស្សឈឺ មនុស្សចាស់ ចូលទៅ
ក្នុងព្រះរាជវាំង ឬឲ្យជួបប្រទះក្នុងទីណាមួយឡើយ ។ ព្រះសិទ្ធត្ថរាជ-
កុមារ គង់នៅជាសុខសប្បាយ ហោមរោមហែហមដោយរាជបរិពារស្រី
សុំក្រមការសុទ្ធសឹងក្រមុំមានរូបល្អៗ ច្រៀងរាំប្រគំដេញដំភ្លេងតូរ្យតន្ត្រី
ថ្វាយគ្រប់ទិនទិវារាត្រី ដើម្បីឲ្យកើតកើនព្រះទ័យគ្រប់ពេលវេលា ។

ថ្ងៃមួយ, ទ្រង់ប្រថាប់លើរថ មានឆន្នអាមាត្យជាសារថី ស្តេចប្រពាត-
ឧទ្យានទ្រង់ទតព្រះនេត្រទៅឃើញមនុស្សចាស់ ស្គាំងស្គមស្លេកស្លាំង
ខ្នងកោងក្រង់ ដៃកាន់ឈើច្រត់ កំពុងដើរញ័រទទ្រេតទ្រោតបន្តិចៗ យោង
តែអាត្មាលំបាកស្ទើរតែមិនរួច ទ្រង់ភ្ញាក់ស្មារតីព្រឺតដោយទ្រង់ជាអ្នកគិត
ច្រើនស្រាប់ ទើបត្រាស់សួរភ្លាមទៅឆន្នអាមាត្យថា “មនុស្សអ្វីនុ៎ះហ្ន៎?” ។
ឆន្នអាមាត្យទូលតបថា: “មនុស្សនេះគឺមនុស្សចាស់” ។ ទ្រង់ត្រាស់សួរ
តទៅទៀតថា “មនុស្សចាស់នេះ កើតមកពីកំណើតតែម្តងដូច្នេះឬ? ។
ឆន្នអាមាត្យតបថា “សូមទ្រង់មេត្តាប្រោស! មិនមែនទេ ពីដើមមនុស្ស
នេះនៅវ័យក្មេងចៅដោះ ជាមនុស្សកម្លោះ មានរូបរាងល្អល្ពេញ
ល្ពៅ ហើយមាំមួនផង” ។ ព្រះអង្គត្រាស់សួរដោយឆ្ងល់ក្នុងព្រះទ័យថា:
“មានមនុស្សដូច្នេះច្រើនណាស់ទៅឬ?” ។ ឆន្នអាមាត្យទូលតបថា:
“សូមទ្រង់ជ្រាប, មានច្រើនណាស់ នេះជាធម្មតារបស់មនុស្សយើង
តែងកើតឡើង ក្មេងហើយចាស់គ្រាំគ្រា បើមិនទាន់ដល់ពេលស្លាប់ទេ

កំស្គាំងស្គមស្លេកស្លាំងគ្រាំគ្រាទូរន់ទូរា តែយ៉ាងនេះគ្រប់ៗគ្នា" ។ ព្រះអង្គត្រាស់សួរទៀតថា: "ចុះដូចរូបខ្ញុំនេះ ដូចគេពលគ្នាដែរ ឬដូចម្ដេច?" ។ ឆន្នអាមាត្យទូលតបថា: "រូបកាយទ្រង់ព្រះករុណា ក៏ដូចជាគេទាំងអស់គ្នាដែរ មិនប្លែកគ្នាទេ" ។ លុះទ្រង់ព្រះសណ្ដាប់ចប់ហើយ ទ្រង់គ្រវីព្រះសិរដោយស្លុតព្រះទ័យយ៉ាងខ្លាំង ឬតដូចជារន្ទះបាញ់មកក្បែរព្រះអង្គ ។

ថ្ងៃមួយ ជាលើកទីពីរ ព្រះអង្គប្រថាប់លើរថ ស្ដេចចេញទៅប្រពាតឧទ្យាន មានឆន្នអាមាត្យជាសារថីដូចទៀត ទ្រង់ទតព្រះនេត ឃើញមនុស្សឈឺដេកក្បែរមគ្គវិថី មានខ្លួនប្រឡាក់ដោយធូលីស្រមូស កំពុងស្រែកថ្ងូរព្រួសម្ងួងគ្រលួច មុខគួរឲ្យអាណិតយ៉ាងស្លុតចិត្តថា: "ម៉ែអើយៗ! ជួយផង" ។ ទ្រង់ត្រាស់ក្ខាងសួរថា: "នែឆន្ន! មនុស្សអ៊ុំនុះហ្ន៎?" ។ ឆន្នអាមាត្យក្រាបបង្គំទូលហូរហែឲ្យជ្រាបថា: "សូមព្រះមេត្តាប្រោស! មនុស្សយើងមានព្យាធិជាសត្រូវសង្កត់សង្កិនបៀតបៀនឲ្យឈឺចាប់ទល់ទុក្ខវេទនាយ៉ាងនេះដូចគ្នាទាំងអស់ មិនមានអ្នកណាជួយរំលែកទុក្ខអ្នកណាបានទេ" ។ លុះទ្រង់បានព្រះសណ្ដាប់ហើយ មានព្រះទ័យញ័ររន្ធត់ដូចជារូបព្រះច័ន្ទ្រនៅក្នុងទឹកកំពុងរលក ។

(មានត)

# អរិយទ្រព្យ ៧ ប្រការ

ពាក្យដែលយើងធ្លាប់ហៅថា "អរិយទ្រព្យនេះ" ជាពាក្យធ្លាប់ត្រចៀមត្រចៀកមកហើយ, បាលីហៅថា "អរិយធន" ប្រែថា "ទ្រព្យដ៏ប្រសើរ" ។ ទ្រព្យទាំងអស់ក្នុងលោកដែលសម្រាប់ប្រើប្រាស់ចាយវាយរាប់តាំងអំពីមាសប្រាក់ផ្ទះសម្បែងជាដើម ឬហៅដោយរួបរួម ទ្រព្យទាំងអស់នោះមានពីរយ៉ាងគឺ វិញ្ញាណក: ទ្រព្យដែលមានវិញ្ញាណបានដល់គោក្របីជាដើម ១, អវិញ្ញាណក: ទ្រព្យដែលឥតវិញ្ញាណមានមាសប្រាក់ជាដើម ១ ។ ទ្រព្យទាំងនេះ លោកមិនបានហៅថា អរិយទ្រព្យទេ ព្រោះជាទ្រព្យដែលតែងវិនាសទៅដោយទឹកលិច, ដោយភ្លើងឆេះ, ដោយចោរលួចប្លន់ ឬដោយអន្តរាយណាមួយ ។

អរិយទ្រព្យ ប្រែថា "ទ្រព្យដ៏ប្រសើរ, ទ្រព្យដ៏ខ្ពង់ខ្ពស់, ទ្រព្យជាស្ថាពរ" ដែលមិនអាចវិនាសដោយអន្តរាយណាមួយមានទឹកលិច ឬចោរលួចជាដើម ។ ពាក្យថាទ្រព្យដ៏ប្រសើរឬខ្ពង់ខ្ពស់នេះ សំដៅយកទ្រព្យដែលឋិតថេរខ្ជាប់ខ្ជួនតាំងនៅក្នុងទីឆ្ងាយអំពីសេចក្តីអន្តរាយគ្រប់យ៉ាង ។ អរិយទ្រព្យ កាលបើមាននៅក្នុងសន្តានចិត្តនៃបុរសស្ត្រីណាមួយ ក៏រមែងមិនលំបាកក្នុងការរៀបចំទុកដាក់ឡើយ ។

## អរិយទ្រព្យនេះមាន ៧ ប្រការ

១ — សទ្ធា សេចក្តីជឿចំពោះហេតុផលដែលគួរជឿ:

២ — សីលៈ ការគ្រប់គ្រងកាយវាចាឲ្យមានសណ្ដាប់ធ្នាប់ល្អ ;

៣— ហិរិ សេចក្ដីខ្មាសបាប ឬអំពើទុច្ចរិត ;

៤ — ឱត្តប្បៈ សេចក្ដីខ្លាចរអាចំពោះបាបឬ ទុច្ចរិត ;

៥ — ពាហុសច្ចៈ ភាពនៃបុគ្គលអ្នកមានការសិក្សារៀនសូត្រច្រើន;

៦ — ចាគៈ ការលះបង់វត្ថុណាមួយ ឲ្យជាប្រយោជន៍ទូទៅ ;

៧ — បញ្ញា ការចេះដឹងយល់ច្បាស់ប្រយោជន៍ដែលមានសារៈ ឬឥតសារៈ ។

អរិយទ្រព្យទាំងនេះមានគោលដែលគួរលើកឡើងអធិប្បាយមាន ៤ យ៉ាង គ្រប់អរិយទ្រព្យទាំង ៧ ប្រការគឺ អរិយទ្រព្យមួយៗ មានគោលបួនៗ ដូចគ្នាទាំងអស់ ។

គោល ៤ យ៉ាងគឺៈ

ក) អត្ថតោ ដោយអត្ថ ឬ ដោយសេចក្ដី ;

ខ) លក្ខណតោ ដោយលក្ខណៈ;

គ) បភេទតោ ដោយប្រភេទ ;

ឃ) អានិសំសតោ ដោយអានិសង្ស ។

ពាក្យថា “ដោយអត្ថ” បានដល់គុណធម៌ដ៏ឧត្ដម សម្រាប់ញុំាង

សេចក្តីត្រិះរិះឲ្យកើតឡើងដល់សាមីខ្លួនអ្នកត្រិះរិះ មិនញុំាងសេចក្តីឲ្យភាន់ច្រឡំដោយហេតុណាមួយ ឲ្យកើតឡើងដល់បុគ្គលអ្នកចេះដឹងឡើយ ។

ពាក្យថា "ដោយលក្ខណៈ" សំដៅយកហេតុការណ៍ដែលអាចកំណត់ចំណាំបានដោយដំណើរខាងក្នុងសន្តានរបស់បុគ្គល ដែលសំដែងចេញមកខាងក្រៅគួរឲ្យអ្នកផងសំគាល់បាន ។

ពាក្យថា "ដោយប្រភេទ" បានដល់ការចែកអត្ថបទនៃធម៌ដោយពួកផ្សេងៗគ្នា ។

ពាក្យថា "ដោយអានិសង្ស" សំដៅយកសេចក្តីល្អ ដែលហូរមកឬ ផ្តល់នូវសេចក្តីសុខសេចក្តីចំរើនហុចឲ្យដល់បុគ្គលអ្នកប្រព្រឹត្តដោយជាក់ច្បាស់តាំងអំពីបច្ចុប្បន្នកាលនេះទៅ ។

### អធិប្បាយចំពោះអរិយទ្រព្យមួយៗ

### ១ — សទ្ធា

សទ្ធា ដោយអត្ថ បានដល់ចេតសិកធម៌ផ្នែកខាងកុសលសុទ្ធមិនមែនលាយដោយអកុសលផងទេ ។ សទ្ធាជាកុសលជាតិ ដែលអាចកែប្រែបត់និស្ស័យរបស់មនុស្ស ដែលធ្លាប់ប្រព្រឹត្តអាក្រក់ ធ្លាប់វៀចឲ្យទៅជាល្អ ឲ្យទៅជាត្រង់បាន ឬថា សទ្ធានេះ សម្រាប់បដិវត្តន៍ក្នុងផ្លូវចិត្តរបស់បុគ្គលក្នុងលោកបាន ។ សទ្ធា ជាប្រធាននៃកុសលធម៌ទាំងពួងអាចប្រស់ព្រំ ស្រោចស្រប់ផ្សព្វផ្សើម កែខែកុសលធម៌ឯទៀតៗ ឲ្យ

ប្រព្រឹត្តល្អទៅតាមខ្លួនបាន ។ វត្ថុដែលឆ្អាបមានត្រីសាច់ជាដើម ឬអាហារណាមួយ ត្រូវមានអំបិលជាប្រធាន ជាធំលើសវត្ថុឆ្អាបទាំងអស់យ៉ាងណា, គ្រឿងបង្អែមមាននំកូរ នំគម នំព្រាំ ជាដើម ត្រូវអាស្រ័យស្ករ មានស្ករជាប្រធាន ជាធំលើគ្រឿងបង្អែមទាំងអស់ គឺថា បង្អែមគ្រប់មុខតែងកើតមកអំពីស្ករ យ៉ាងណា, សទ្ធា ក៏យ៉ាងនោះដែរ គឺថា កុសលធម៌ទាំងឡាយ ជាសហជាតធម៌ទាក់ទងដោយសទ្ធាជាដើម ត្រូវតែអាស្រ័យសទ្ធាទើបអាចប្រព្រឹត្តទៅបាន បើមិនមានសទ្ធាជួយជាកម្លាំងផងទេ រមែងប្រព្រឹត្តទៅដោយខុសផ្លូវ ឬ ឃ្លៀងឃ្លាតពុំខាន ។

សទ្ធា ដោយលក្ខណៈ សំដៅយកហេតុផលដែលគួរជឿ, កាលបើជឿដែលប្រកបដោយសេចក្តីត្រិះរិះត្រូវ ហៅថា ញាណសម្បយុត្ត, កាលបើជឿដោយមិនបានត្រិះរិះ គឺជឿតាមទម្លាប់ទំនៀមរបស់មនុស្សសាមញ្ញ ប្រាសចាកបញ្ញា ហៅថា ញាណវិប្បយុត្ត ។

សទ្ធា ដោយប្រភេទ សំដៅយក ប្រភេទ៤យ៉ាង គឺ កម្មសទ្ធា សេចក្តីជឿចំពោះកម្មទាំងកល្យាណកម្មនិងបាបកម្ម ១, វិបាកសទ្ធា សេចក្តីជឿចំពោះផលរបស់កម្ម ១, កម្មស្សកតាសទ្ធា សេចក្តីជឿ-ចំពោះសត្វដែលមានកម្មជារបស់ខ្លួន ១, តថាគតពោធិសទ្ធា សេចក្តីជឿចំពោះការត្រាស់ដឹងនៃព្រះតថាគត ១ ។

សទ្ធា ដោយអានិសង្ស សំដៅយកផលការដែលអាចឲ្យសម្រេច ឃើញជាក់ច្បាស់ចំពោះប្រយោជន៍ណាមួយ ទាំងផ្លូវលោកផ្លូវធម៌ ។ ករណីយកិច្ចទាំងអស់ ដែលអាចដឹកនាំបុគ្គលឲ្យប្រព្រឹត្តទៅបាន គឺព្រោះអាស្រ័យកម្លាំងសទ្ធា មានសទ្ធាជាគូដៃ ជាគុណនាំឲ្យសម្រេចប្រយោជន៍នឹងសេចក្ដីសុខចំរើន ទាំងឥធលោកនឹងបរលោក ។ សទ្ធាកាលបើកើតក្នុងចិត្តនៃបុរសស្ត្រីណា រមែងកំចាត់បង់នូវអស្សទ្ធិយៈ គឺសេចក្ដីមិនជឿរបស់បុរសស្ត្រីនោះឲ្យខ្ចាត់អស់ចេញអំពីសន្ដានបាន ។

សេចក្ដីជឿចូលចិត្តចំពោះកិច្ចការក្នុងផ្លូវលោកក្ដី ផ្លូវធម៌ក្ដី ដែលប្រកបដោយហេតុផល ហៅថាសទ្ធា ក្នុងព្រះពុទ្ធសាសនា ។ ការចូលចិត្តជឿដោយឥតហេតុផល គឺជឿតាមប្រពៃណីទម្លាប់ទំនៀមគេ ៗ គ្នា ដែលប្រាសចាកហេតុផល មានការជឿមង្គលកុហកឬមង្គលភ្ញាក់ផ្អើលជាដើម មិនហៅថាសទ្ធាក្នុងព្រះពុទ្ធសាសនាទេ ។

## ២ — សីល

សីល ដោយអត្ថ បានដល់គុណជាតដ៏ស្អាតបរិសុទ្ធជាគ្រឿងត្រជាក់ត្រជុំ ជាកំពូលជាទីតាំងនៃកុសលធម៌ ជាគ្រឿងសម្រាប់ទ្រទ្រង់ទុកនូវកុសលធម៌ទាំងពួងឲ្យមានកាយវាចាល្អជាប្រក្រតី ។

សីល ដោយលក្ខណៈ បានដល់ការតាំងចិត្តឲ្យត្រជាក់ក្នុងការសង្រួមរក្សាកាយវាចាឲ្យរៀបរយ មិនឲ្យប៉ះពាល់សិទ្ធិសេរីភាពរបស់មនុស្សសត្វដទៃ, ប្រាសចាកអំពើទុច្ចរិត ឬទោសណាមួយដែលអ្នកផងគប្បីតិះដៀលបាន ។

សីល ដោយប្រភេទ បានដល់ប្រភេទនៃសីលជាច្រើនយ៉ាង បើពោលដោយខ្លីមាន ២ យ៉ាងគឺ: គហដ្ឋសីល សីលរបស់គ្រហស្ថមាននិច្ចសីលជាដើម ១, បព្វជិតសីល សីលរបស់បព្វជិតមានបាតិមោក្ខសំវរៈសីលជាដើម ១ ។

សីល ដោយអានិសង្ស បានដល់ការកំចាត់បង់នូវកិលេសគ្រោតគ្រាតដែលកើតឡើងអំពីកាយវាចា, មួយទៀត សីលជាអាទិកល្យាណជាច្បាប់ដំបូងក្នុងថ្នាក់ខាងដើម អាចឈានទៅរកគុណធម៌ជាន់ខ្ពស់ ដូចកាំជណ្ដើរថ្នាក់ក្រោមដែលអាចនាំដើរឲ្យឡើងទៅកាន់ទីខ្ពស់បាន, មួយវិញទៀត សីលដែលបុគ្គលរក្សាល្អហើយ រមែងមានផលានិសង្សដ៏ធំជាបច្ច័យដើម្បីសមាធិ ប៉ុណ្ណោះជាដើម ។ សីលអាចឲ្យសម្រេចប្រយោជន៍គឺសេចក្ដីសុខចំរើនតាំងអំពីបច្ចុប្បន្ននេះ រហូតដល់បរលោក ។ សីលជាគុណជាតសម្រាប់ដោះស្រាយពៀរវេរាក្នុងរវាងមនុស្សផងគ្នា ឬ សត្វតិរច្ឆាន, សីលជាគ្រឿងកំចាត់បង់នូវភ័យទាំងពួង មានអត្តានុវាទភ័យ

ជាដើម ។ សីល រមែងញុំាងប្រយោជន៍ឲ្យសម្រេចបានដរាបដល់ចាស់ជរា, សីល រមែងនាំផលដ៏ក្សេមក្សាន្តមកប្រគល់ឲ្យដល់អ្នករក្សា មិនរើសថាបុគ្គលចាស់ឬក្មេង បុរសឬស្ត្រីឡើយ ។

## ៣ — ហិរិ

ហិរិ ដោយអត្ថ សំដៅយកសេចក្ដីខ្មាសក្នុងការប្រព្រឹត្តិអាក្រក់ មិនមែនខ្មាសដោយសំគាល់ថា អាត្មាអញមិនគួរដល់ជាតិ ឬដល់ត្រកូលនោះឡើយ គឺសេចក្ដីខ្មាសអៀនចំពោះអំពើបាប ដោយផ្ចង់ចិត្ត ស្អប់សេចក្ដីប្រព្រឹត្តិទុច្ចរិតដោយកាយវាចាចិត្តដោយពិត ។

ហិរិ ដោយលក្ខណៈ បានដល់និស្ស័យចិត្តដែលធ្លាប់មានក្នុងសន្ដាន មានសភាពដ៏ស្ងួតបូត សំដែងអាការចេញមកខាងក្រៅគួរឲ្យអ្នកផងសំគាល់បានថាជាបុគ្គលបរិសុទ្ធកាយ វាចា ចិត្ត ប្រៀបដូចមនុស្សកំឡោះ ឬក្រមុំ ជាអ្នកស្រឡាញ់ការស្អាត ឧស្សាហ៍ងូតទឹកជម្រះរាងកាយ, កាលបើប្រទះគ្រឿងប្រឡាក់ស្មោកគ្រោក ក៏មានសេចក្ដីធុញទ្រាន់ក្រៃលែង ។

ហិរិ ដោយប្រភេទ បានដល់ប្រភេទនៃហិរិដោយសមុដ្ឋាន ៤ យ៉ាង គឺ គិតថាអាត្មាអញជាអ្នកមានជាតិ ត្រកូលខ្ពស់ ឬ ត្រកូលដ៏សមគួរ ១, អាត្មាអញ ជាអ្នកមានវ័យចាស់ទុំ ឬដឹងក្ដីខុសត្រូវ ១, អាត្មាអញ ធ្លាប់ជាអ្នកក្លៀវក្លាក្នុងការប្រព្រឹត្តិធម៌វិន័យ ១, អាត្មាអញ ជាអ្នក

សិក្សារៀនសូត្រចេះដឹងច្រើន ១ ។ កាលបើបុគ្គលពិចារណាឃើញច្បាស់តាមប្រភេទដូច្នេះ ក៏រមែងអៀនខ្មាសចំពោះអំពើបាប មិនហ៊ានប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្តឡើយ ។

ហិរិ ដោយអានិសង្ស សំដៅយកសេចក្តីសរសើរនិងសេចក្តីគោរពអំពីបុគ្គលដទៃ សត្វដទៃ ដែលអាចបានទទួលផលអភ័យទានអំពីបុគ្គលអ្នកមានហិរិដោយពិត ។ ហិរិ ជាគុណជាតិដ៏ក្សេមក្សាន្តអាចឲ្យបានសេចក្តីសុខសរសើរ ក៏បាត់បង់នូវគរហានិន្ទាក្នុងលោកនេះបាន ។

## ៤ — ឱត្តប្បៈ

ឱត្តប្បៈ ដោយអត្ថ បានសេចក្តីថា ការខ្លាចបាបឬខ្លាចទុច្ចរិតចំពោះខ្លួនឯងដោយពិតៗ មិនមែនខ្លាចចំពោះតែមាតាបិតា គ្រូអាចារ្យអ្នកគ្រប់គ្រង ឬព្រះរាជអាជ្ញានោះទេ ។

ឱត្តប្បៈ ដោយលក្ខណៈបានដល់ការខ្លាចអំពើទុច្ចរិត ខ្លាចកំណើតទុគ្គតិជាគ្រឿងសំគាល់គឺប្រាជ្ញាឃើញច្បាស់ថា សត្វលោកសុទ្ធតែមានកម្មជារបស់ខ្លួន មានកម្មជាអ្នកឲ្យកំណើត, បើបុគ្គលធ្វើកល្យាណកម្ម គឺអំពើជាបុណ្យនឹងបានផលជាសុខ, បើធ្វើបាបកម្មនឹងបានផលជាទុក្ខ ។ ឱត្តប្បៈនេះ កាលបើមានក្នុងសន្តាននៃបុគ្គលណា អាចញ៉ាំងបុគ្គលនោះឲ្យរួចចាកទុគ្គតិ គឺដំណើរអាក្រក់ទាំងបច្ចុប្បន្ននិងបរលោក ដែលអ្នកផងគួរសំគាល់បានថាជាមនុស្សមានសីលធម៌ ។

ឱត្តប្បៈ ដោយប្រភេទ សំដៅយកប្រភេទនៃបុគ្គលមានមាតាបិតាជាដើមផង ប្រភេទនៃអបាយភូមិមាននរកជាដើមផង ។ ការខ្លាចរអាដោយសេចក្ដីគោរពចំពោះលោកគឺប្រជាជន ឬខ្លាចរអាចំពោះផលអាក្រក់ មានកំណើតនៃនរកប្រេតជាដើម ហើយមានចិត្តរញ្ជួយក្ដៅក្រហាយមិនហ៊ានប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត ។

ឱត្តប្បៈ ដោយអានិសង្ស សំដៅយកសីតិភាព គឺភាពនៃចិត្តដ៏ត្រជាក់មិនក្ដៅពេលពលចំពោះខ្លួនឯង មិនញុំាងអ្នកដទៃឲ្យក្ដៅក្រហាយ ។ ឱត្តប្បៈ ជាគុណជាតនាំមកនូវសន្តិសុខ ជាសាធារណៈទាំងខ្លួនឯងទាំងអ្នកដទៃ អាចទទួលការឃុំគ្រងរក្សាសត្វលោកឲ្យតាំងនៅជាសុខ មិនឲ្យមានការប្រេះឆាសាមគ្គីធម៌ក្នុងរវាងនៃគ្នានឹងគ្នាបាន ។

## ៥ — ពាហុសច្ចៈ

ពាហុសច្ចៈ ដោយអត្ថ បានដល់ការស្ដាប់ ឬ ការសិក្សារៀនសូត្រច្រើន មានសេចក្ដីឆ្លៀវឆ្លាសវាងវៃបែកធ្លាយក្នុងអត្ថ ក្នុងធម៌, មានការយល់ដ៏ជ្រាលជ្រៅអាចសំដែង អាចនិយាយបានដោយឥតទើសទាល់ ព្រោះបានទទួលការសិក្សារៀនសូត្របេះដឹងច្រើន ។

ពាហុសច្ចៈ ដោយលក្ខណៈ សំដៅយកភាពនៃបុគ្គលជាពហុ-ស្សូតដែលមានអាការគួរឲ្យអ្នកផងស់គាល់បាន មានភាពជាអ្នកប្រសប់

ប៉ិនប្រសប់ក្នុងការនិយាយ ឬ ក្នុងការសរសេរតែងសេចក្ដីដែលចេញដំណើរល្អមកខាងក្រៅគួរឲ្យគេចំណាំបានដោយស្នាដៃល្អដោយវោហារពុំខាន ។

**ពាហុសច្ចៈ** ដោយប្រភេទ បានដល់ពាហុសច្ចៈពីរយ៉ាងគឺអាគារិកពាហុសច្ចៈ ភាពនៃការសិក្សារៀនសូត្រច្រើនជារបស់គ្រហស្ថ ១, អនាគារិកពាហុសច្ចៈ ភាពនៃការសិក្សារៀនសូត្រច្រើនជារបស់អ្នកបួស ១. ។ ការសិក្សារៀនសូត្រវិទ្យាសាស្ត្រផ្សេង ៗ ក្នុងផ្លូវលោក គឺនីតិសាស្ត្រ (វិជ្ជាខាងច្បាប់), វេជ្ជសាស្ត្រ (វិជ្ជាខាងពេទ្យ), យុទ្ធសាស្ត្រ (វិជ្ជាខាងទាហាន), យន្តសាស្ត្រ (វិជ្ជាខាងគ្រឿងចក្រ) សិល្បសាស្ត្រ (វិជ្ជាខាងហត្ថកម្មធ្វើគ្រឿងផ្សេងៗ សម្រាប់ប្រើប្រាស់) ប៉ុណ្ណេះជាដើម ហៅថា "អាគារិកពាហុសច្ចៈ" ឬហៅថា "ពាហុសច្ចៈផ្លូវលោក" ដូច្នេះក៏បាន ។

ការសិក្សារៀនសូត្រ ក្នុងផ្លូវធម៌ បានដល់ការរៀនព្រះបរិយត្តិធម៌ក្នុងព្រះពុទ្ធសាសនាគឺព្រះត្រៃបិដក ដើម្បីឲ្យចេះដឹង យល់ច្បាស់លាស់ក្នុងផ្លូវធម៌ ហៅថា "អនាគារិកពាហុសច្ចៈ" ឬហៅថា "ពាហុសច្ចៈផ្លូវធម៌ដូច្នេះក៏បាន" ។

**ពាហុសច្ចៈ** ដោយអានិសង្ស សំដៅយកការស្គាល់ហេតុផល បុណ្យ បាប គុណ ទោស ព្រោះអាស្រ័យការចេះដឹងច្រើន ។ ពាហុសច្ចៈអាចកំចាត់បង់នូវសេចក្ដីល្ងង់ខ្លៅ ជាគុណជាតនាំឲ្យមានឧត្តមគតិ គឺដំណើរខ្ពង់ខ្ពស់ថ្លៃថ្នូរ, នាំឲ្យមានសមត្ថភាពគ្រប់គ្រាន់, នាំឲ្យបានទទួល

ឋានៈជាអ្នកប្រាជ្ញក្នុងផ្លូវលោក ឬផ្លូវធម៌. នាំឲ្យបានកិត្តិយសជាអ្នកបំភ្លឺដល់ជាតិត្រកូលឲ្យស្គាល់សារៈប្រយោជន៍, នាំឲ្យមានវឌ្ឍនធម៌ បានសេចក្ដីសុខចំរើនដោយភោគសម្បទ៍នឹងបរិវារសម្បទ៍ឃើញជាក់លាក់ក្នុងលោកនេះ ។

## ៦ — ចាគៈ

ចាគៈ ដោយអត្ថ បានដល់ការចាយវាយប្រាក់កាស ដើម្បីឲ្យជាប្រយោជន៍ក្នុងព្រះពុទ្ធសាសនា ឬក្នុងប្រទេសជាតិ ដូចកសាងវត្តមានវិហារ កុដិ សាលាជាដើម សម្រាប់បំរើព្រះពុទ្ធសាសនា ឬក៏ចាយវាយប្រាក់កាសសម្រាប់កសាងសម្ភារៈផ្សេងៗ មានសាលារៀន, មន្ទីរពេទ្យ, សង់ស្ពាន, លើកថ្នល់, ជីកព្រែកជាដើម សម្រាប់ទុកបំរើប្រទេសជាតិជំនួសអាយុជីវិតយើងតវែងទៅ ដើម្បីឲ្យបានសុខស្រួលដល់បច្ឆាជន ។

ចាគៈ ដោយលក្ខណៈ បានដល់ការបរិច្ចាគដើម្បីលះបង់មច្ឆរិយៈនឹងលោភៈមិនឲ្យជាប់ជំពាក់ក្នុងសន្ដាន ប្រកបដោយភាពជាអ្នកមានចិត្តទូលាយដល់ពួកជនជាសាធារណៈដែលអ្នកផងគប្បីសំគាល់បានថាជាអ្នកធ្វើប្រយោជន៍ដល់ព្រះពុទ្ធសាសនា ឬដល់ប្រទេសជាតិ ។

ចាគៈ ដោយប្រភេទ បានដល់ប្រភេទនៃចាគៈ ២ យ៉ាងគឺៈ អាមិសចាគៈ លះបង់វត្ថុផ្សេងៗ មានប្រាក់កាសជាដើម ១, ធម្មចាគៈ

លះបង់ធម៌គឺការបង្រៀន រៀនប្រដៅធម៌ ឬតែងសៀវភៅច្បាប់ទម្លាប់ ដើម្បីឲ្យអ្នកដទៃចេះដឹងផងដោយមិនខ្លាចនឿយហត់ ១ ។

ចាគៈ ដោយអានិសង្ស សំដៅយកការបំណាយប្រាក់កាស ទំនុកបំរុងសាសនា ឬទំនុកបំរុងប្រទេសជាតិរបស់ខ្លួន ដោយផ្លូវសិក្សារៀនសូត្រ, ដោយកិច្ចកសាងសម្ភារៈមានសាលារៀនជាដើម ជាប្រយោជន៍ដល់សាសនាដល់ប្រទេសជាតិតទៅអនាគត ។ ចាគៈនេះជាគុណធម៌១ដែលឲ្យសម្រេចប្រយោជន៍ជាសាធារណៈដល់ប្រទេសជាតិជាច្រើន, ចាគៈនេះ ជាធម៌ដែលបុគ្គលតែងសរសើរទាំងបច្ចុប្បន្ននឹងអនាគត ។ លាភយសសរសើរ សុខ តែងមានដល់សាមីខ្លួនអ្នកមានចាគ-ធម៌ផង ដល់បុច្ចាជនដែលបានទទួលផលរបស់ចាគធម៌ផង ។ ចាគ នេះមានគុណានិសង្សអាចឲ្យកំចាត់បង់នូវមច្ឆរិយៈនឹងលោភៈក្នុងសន្តាន ដើម្បីធ្វើចិត្តឲ្យបរិសុទ្ធ មិនឲ្យជាប់ជំពាក់ក្នុងទ្រព្យសម្បត្តិឬក្នុងជីវិត ។ ចាគៈនេះជាធម៌សម្រាប់កសាងជីវិតរបស់ខ្លួនព្រមទាំងជីវិតរបស់ប្រទេសជាតិឲ្យរស់នៅវែងឆ្ងាយតទៅអនាគត ឲ្យមានវឌ្ឍនធម៌ ឲ្យបានសេចក្តីសុខ-ចំរើនរុងរឿងថ្កុំថ្កើងឃើញជាក់ច្បាស់តាំងអំពីបច្ចុប្បន្ននេះរហូតដល់បរលោកព្រមទាំងជាអនុស្សាវរីយ៍របស់ចាគីបុគ្គលតរៀងទៅ ។

### ៣– បញ្ញា

បញ្ញា ដោយអត្ថ បានដល់ការដឹងច្បាស់ ឬដឹងទូទៅ គឺដឹង

ច្បាស់ហេតុផលទាំងខាងល្អទាំងខាងអាក្រក់ ទាំងខាងគតិធម៌ ទាំងខាងគតិលោក ។ បញ្ញា ជាធម្មជាតិដែលកើតមកអំពីពាហុសច្ចៈ, បញ្ញាជាផល,ពាហុសច្ចៈ ជាហេតុ ។ ការបេះដឹងឈ្វេងយល់ក្នុងកិច្ចការពក់ព្រ័ន្ធ, ការផាប់បេះដឹង, ផាប់ចាប់សេចក្ដីបានយូរមិនភ្លេចភ្លាំងស្មារតី ហៅថាបញ្ញាបានទាំងអស់ ។

បញ្ញា ដោយលក្ខណៈ សំដៅយកការពន្យល់ស្គាល់ដំនាញដែលជាគ្រឿងបំណាំរបស់បុគ្គលថា "នេះជាហេតុនៃទុក្ខ, នេះជាហេតុនៃសុខ, នេះជាផ្លូវសម្រាប់ចេញទៅ ដើម្បីរួចចាកទុក្ខ នេះមិនមែនជាផ្លូវដើម្បីរួចចាកទុក្ខដែលបុគ្គលគួរកំណត់សំគាល់ដោយឧបាយរបស់ខ្លួនបាន" ។

បញ្ញា ដោយប្រភេទ បានដល់ប្រភេទនៃបញ្ញានេះមានច្រើនយ៉ាង តែបើពោលដោយសង្ខេបមាន ២ យ៉ាងគឺៈ លោកិយបញ្ញា ១, លោកុត្តរបញ្ញា ១ ។

បញ្ញារបស់មនុស្សដែលមានកិលេសជាប់ពាក់ទងនៅក្នុងលោកដែលមិនអាចដោះស្រាយបញ្ហាក្នុងការកើតស្លាប់នៅក្នុងលោក ប៉ុន្តែគ្រាន់តែមានវិជ្ជានធម៌ក្នុងលោកបាន ហៅថា "លោកិយបញ្ញា" ។

បញ្ញារបស់មនុស្សជាន់ខ្ពស់ គឺព្រះអរហន្តខីណាស្រពដែលអស់កិលេសាសវៈមិនជាប់នៅក្នុងលោក, ជាបញ្ញារើខ្លួនចេញចាកលោក

អាចដោះស្រាយបញ្ហាក្នុងការកើតស្លាប់ក្នុងលោកបាន ប៉ុណ្ណេះជាដើម ហៅថា "លោកុត្តរបញ្ញា" ។

បញ្ញា ដោយអានិសង្ស សំដៅយកគុណជាតិម្យ៉ាង ហៅថាជាចេតសិកធម៌ខាងកុសល ដែលមាននៅក្នុងសន្ដានចិត្តនៃបុគ្គលណារមែងដឹកនាំបុគ្គលនោះឲ្យភ្លឺស្វាងរុងរឿងឆាប់យល់កិច្ចការគ្រប់ចំពូកបាន ។ ពន្លឺព្រះចន្ទ្រ, ពន្លឺភ្លើង, ពន្លឺព្រះអាទិត្យ រាប់ថាជាពន្លឺគ្រាន់តែសម្រាប់ចក្ខុប៉ុណ្ណោះ ឬហៅថា ជាពន្លឺសម្រាប់លោកធម្មតា មិនមែនជាពន្លឺប្រសើរខ្ពង់ខ្ពស់ ដូចពន្លឺពោលគឺបញ្ញាឡើយ ។ សង្ខារលោក គឺដី, ទឹក ភ្លើង ខ្យល់ ជាសភាវៈដែលសង្ខារធម្មតាបានកសាងមកហើយ ។ ឧបាយប្រាជ្ញារបស់បុគ្គលអ្នកបានសិក្សាចេះដឹងច្រើន, គេបានពិនិត្យសង្កេតស្ទាបស្ទង់រក, បានពិសោធមើលកិច្ចការ, ផ្សំហេតុផល, ផ្សំធាតុ, តាមវិទ្យា-សាស្ត្រ, តាមរូបនិយម, តាមគម្រោងផ្សេងៗ អាចកសាងដីឲ្យទៅជាទីក្រុង, ឲ្យទៅជាផ្ទះ, ទៅជាប្រាសាទ, ទៅជាប្រាង្គបាន ។ គេកសាងទឹកធម្មតាឲ្យទៅជាទឹកថ្លា, ទឹករាវ, ទឹករឹង គឺទឹកកក ឬទឹកថ្នាំភេសជ្ជៈមានរសផ្អែម រសល្វីងជាដើម ។ គេកសាងភ្លើងធម្មតា ឲ្យទៅជាភ្លើងអគ្គិសនី, ឲ្យទៅជាភ្លើងមិនក្ដៅ តែមានពន្លឺឆ្លុះបំភ្លឺបានដូចពន្លឺពិល ។ គេកសាងខ្យល់ធម្មតា ឲ្យទៅជាខ្យល់លុះអំណាចរបស់វិទ្យាសាស្ត្រដែលកើតអំពីផ្លិត អំពីកង្ហារ, អំពីគ្រឿងចក្រអាចបឺតបូមសប់យកខ្យល់ធម្មតា

មកប្រើប្រាស់ក្នុងគ្រឿងចក្របាន ។ បញ្ញា ជាគុណជាតិដ៏ប្រសើរបំផុត អាចឲ្យសម្រេចសេចក្ដីប្រាថ្នាគ្រប់យ៉ាង តាំងអំពីគតិលោក ដូចពប់មកដោយសង្ខេបប៉ុណ្ណោះ រហូតដល់គតិធម៌ជាន់ខ្ពស់បំផុត គឺមគ្គ ផល និព្វាន ក៏ព្រោះអាស្រ័យបញ្ញាទាំងអស់ ។

## សេចក្ដីបញ្ចប់

មានពុទ្ធភាសិតក្នុងសគាថវគ្គសំយុត្តនិកាយថា "ពួកសត្វ កាលបើត្រូវសេចក្ដីស្លាប់គ្របសង្កត់ហើយ តែងលះបង់នូវវត្ថុទាំងពួង គឺទាំងទ្រព្យសម្បត្តិក្ដី យសស័ក្ដិក្ដី គ្រួសារក្ដី ញាតិសន្ដានក្ដី ដែលមានប្រយោជន៍តែក្នុងវេលាដែលខ្លួនរស់នៅ សូម្បីសរីរៈរាងកាយក៏ចោលនៅស្ដុកស្ដឹងលើប្រថពី; ទ្រព្យសម្បត្តិនិងសរីរៈទាំងអស់ ឥតជាប់តាមទំនុកបំរុងជួយខ្លួនបានឡើយ មានតែកុសលកម្ម និងអកុសលកម្ម ទើបអាចជួយទំនុកបំរុងជាប់តាមខ្លួនបាន ដូចស្រមោលជាប់តាមប្រាណ" ។ អរិយទ្រព្យ ៧ ប្រការ ចាត់ជាកុសលកម្មដ៏ខ្ពង់ខ្ពស់ សង្គ្រោះថាជាទ្រព្យសម្រាប់ជួយឧបត្ថម្ភតាំងអំពីដំរកាពរហូតដល់កាលខាងមុខ អំពីមរណ-ភាពទៅ ក៏អាចជាប់តាមជាមួយនឹងវិញ្ញាណក្ខន្ធទៅជួយជ្រោមជ្រែងដឹកនាំផ្លូវទៅរកសុគតិកពតទៅទៀត ព្រោះហេតុនោះ ធម៌ទាំង ៧ ប្រការមានសទ្ធាជាដើម ទើបលោកហៅថា អរិយទ្រព្យ ដែលប្រែថាទ្រព្យដ៏ប្រសើរដូចពណ៌នាមកនេះឯង ។

ព្រះទេពសត្ថា សួរ - ហៈយ

## បណ្ឌិតម៉ាល៉ាល៉ៈសេកេរៈ

# អញ្ជើញមកកាន់ប្រទេសកម្ពុជា

ដុកទ័រម៉ាល៉ាល៉ៈសេកេរៈជាអធិបតីពុទ្ធិកសមាគមពិភពលោកនៅលង្កាទ្វីប បានអញ្ជើញមកបំពេញបេសកកម្មខាងសាសនានៅប្រទេសកម្ពុជា ឃើងពីថ្ងៃទី១៧ ឧសភា គ. ស. ១៩៥១ រហូតដល់ថ្ងៃទី២២ ឧសភា ទើបឆ្ពោះទៅកាន់ក្រុងព្រៃនគរ ។ ថ្ងៃដែលលោកអញ្ជើញមកដល់ សមាគមមិត្តសាលាបាលីព្រមទាំងពួកពុទ្ធបរិសទ្យទាំងឡាយ បាននាំគ្នាទៅចាំទទួលលោកឯច្រាំងចំរេះ ឲ្យបានសមរម្យទៅតាមឋានៈលោកជាទូតសាសនា ។ រថយន្តដែលនាំលោកពីសៀមរាបមក បានមកដល់ទីនោះនៅវេលាម៉ោង១៧និង៤៥នាទី លោកដុកទ័របានចេញចាករថយន្តមកគួរសមនឹងអ្នកទទួល លើកដៃឡើងលើសំពះអ្នកទទួលទាំងប្រុសទាំងស្រី ។ ប្រដាប់សំលៀកបំពាក់ជាតិ អាវដៃវែងខ្សែរបំពៀងសំពត់សំឡុយ, បណ្ឌិតម៉ាល៉ាល៉ៈសេកេរៈ មានឫកពារសុភាពគួររាប់អាន ជាអ្នកប្រកបដោយសមានចិត្ត ហាក់ដូចជាមិត្តមួយរូបទើបមកដល់ នាំឲ្យអ្នករង់ចាំលោកទាំងឡាយស្មោះស្ម័គ្រពាក់ទាក់រកគ្រប់ ៗ គ្នា ។

លោកអ្នកប្រាជ្ញខាងពុទ្ធសាសនារូបនេះ រាងក្រអាញដុះពោះ បង្កាមានផ្នត់ដោយសាច់ច្រើន បបូរមាត់ក្រាស់រង្វះធំ មានផ្នត់ធ្លាក់ពីចុងច្រមុះចុះមកក្រោម ដែលគេហៅថាលក្ខណៈក្រឡេកញញឹម ភ្នែកព្រាយ

នូវសេចក្ដីល្អ ជាសធកនៃអ្នកគិតគូរ មុខស្រស់ញញឹម លោកជាអ្នកជាក់ច្បាស់ក្នុងខ្លួនរបស់លោក ហាក់ដូចជាចេះតែទៅមុខជាដរាបមិនរាថយក្រោយ តែទៅមុខយ៉ាងនឹងនួន ។

លុះធ្វើសន្ទនាការជាមួយពួកពុទ្ធបរិសទ្យដោយការគួរសមរួចហើយ លោកបានលាឡើងរថយន្តឆ្ពោះទៅកាន់សណ្ឋាគារ ឡូវ៉ៃយ៉ាល់ ដោយមានរថយន្តចំនួន២០នាំជូនទៅ ។ លោកបណ្ឌិតបានទទួលនូវបដិសណ្ឋារកិច្ចដ៏ស្មោះសរ អំពីពុទ្ធបរិសទ្យក្រុងភ្នំពេញនាពេលដែលលោកបានសំណាក់នៅក្នុងទីក្រុងនោះ បានទទួលលៀងភោជនាហារជាច្រើនកន្លែងនៅគេហស្ថាន លោកគាន់ចូរហេងនឹងលោកជុំទួតជាដើម ក្នុងពេលនោះលោកឆ្លើយដោះសារបញ្ហាផ្សេងៗ យ៉ាងក្បោះក្បាយ ។ លោកបានចូលរួមធ្វើវិសាខបូជាក្នុងគ្រប់វត្តនៅទីក្រុង ហើយនៅរាត្រីជាបន្ទាប់វិសាខបុណ្ណមី លោកបានណែនាំពុទ្ធមាមកជនទាំងឡាយឲ្យសំរួមកាយវាចាចិត្តដើម្បីផ្សាយនូវមេត្តាគ្រាលទូទៅពេញលោកទាំងមូល ។ ចំណែកបេសកកម្មដែលលោកត្រូវបំពេញនោះ លោកបានបញ្ជាក់ក្នុងបាឋកថាដែលលោកបានសម្ដែងក្នុងឧកាសសម្ពោធខឿនព្រះពោធិព្រឹក្សក្នុងបរិវេណសាលាបាលីជាន់ខ្ពស់ ។ យើងសូមស្រង់គោលសំខាន់ៗ មកថ្លែងជូនអ្នកអានស្ដាប់ដូចតទៅនេះ ។

លោកពោលថា អ្នកកាន់ព្រះពុទ្ធសាសនាមានចំនួនតែ៣៥០លាននាក់ ក្នុងប្រទេស២៤ ក្នុងចំនួនប្រជាជន ២.២៦៥លាននាក់គឺថា មានចំនួនពុំទាន់ធួនល្មមនៅឡើយ ប្រសិនបើប្រទេសនានាស្រុះស្រួលគ្នាកាន់ព្រះពុទ្ធសាសនាទូទៅ ភ្លើងសង្គ្រាមមុខជារលត់ជាប្រាកដក្នុងលោកនេះ ព្រោះព្រះពុទ្ធសាសនាប្រដៅមេត្តាធម៌ ឲ្យទំលាក់អាវុធ ទំលាក់ការចងពៀរ ដើម្បីវត្ថុបំណងគឺសន្តិសុខ គប្បីអ្នកកាន់ព្រះពុទ្ធ-សាសនាទាំងឡាយប្រមូលសាមគ្គីនឹងគ្នា ៗ ដោយហេតុចង់ឲ្យមានសាមគ្គីនេះហើយ ទើបសមាគមពិភពលោកបានផ្ជុំអ្នកតំណាងពុទ្ធ-សាសនិកជនគ្រប់ប្រទេសនៅឯកោះលង្កា ដើម្បីឲ្យបានស្គាល់គ្នា ឲ្យបានចរចានឹងគ្នា ធ្វើសហការជាមួយគ្នា ៗ ចំពោះសាមគ្គីធម៌នេះ លោកដុកទ័របានឲ្យន័យថា យើងជាកូនព្រះពុទ្ធតែមួយព្រះអង្គ ប្រតិបត្តិធម៌គ្រូមួយអង្គ គួរយើងរាប់អានគ្នាដូចបងប្អូនបង្កើត លះបង់ការប្រកាន់គណៈការឈ្លោះប្រកែកជជែករកល្អអាក្រក់ពីគ្នា រវាងហីនយានទឹងមហាយាន ជាដើម ដូច្នោះហើយ ទើបពុទ្ធិកសមាគមពិភពលោក បានកំណត់ថ្ងៃវិសាខបូជាឲ្យត្រូវគ្នានឹងឲ្យប្រើទង់សាសនាដូចគ្នា គឺទង់ឆព្វណ្ណរង្សី ទង់នេះចាប់ឲ្យប្រើពីថ្ងៃវិសាខបូជានេះតទៅ នៅគ្រប់ប្រទេសកាន់ពុទ្ធ-សាសនាទាំងអស់ ៗ

ដើម្បីដោះស្រាយការខ្វែងគំនិតគ្នារវាងគណៈផ្សេងៗនៃព្រះពុទ្ធសា-សនា បណ្ឌិតម៉ាលាលៈសេកេរៈ បានស្នើមធ្យោបាយដ៏ប្រពៃមួយថា

លុះត្រាតែមានការរៀនសូត្រជាមួយគ្នា   មានការប្រជុំជាមួយគ្នាជាញឹកញយ ទើបមានការចុះសំរុងគ្នាបាន លោកប្រារព្ធនឹងបង្កើតការសិក្សាសាសនាមួយនៅប្រទេសលង្កា ដែលត្រូវទុកជាមជ្ឈមណ្ឌលនៃការសិក្សានោះ ហើយលោកឲ្យយោបល់ថា   ការអប់រំក្មេងពីតូចៗជាការសំខាន់ណាស់ ព្រោះសន្ដានក្មេងងាយនឹងពត់ជាបំផុត   ហើយគួរបញ្ចូលការសិក្សាពុទ្ធសាសនាក្នុងកម្មវិធីនៃការបង្ហាត់បង្រៀនក្នុងសាលាផង   ការសិក្សានាំឲ្យជឿច្បាស់  នាំឲ្យយល់ត្រូវអំពីព្រះពុទ្ធសាសនា  ។

លោកដុកទ័របានរំលឹកថា កាលដើមឡើយមានតែភិក្ខុ៩អង្គទេជាអ្នកផ្សាយព្រះពុទ្ធសាសនា   អាចបញ្ចុះបញ្ចូលសិស្សបានជាចំនួនច្រើនរហូតដល់ ៣៥០ លាននាក់ក្នុងសម័យនេះ   ប្រសិនបើយើងរួបរួមគ្នាផ្សាយព្រះពុទ្ធសាសនាដោយស្មោះសរ   មុខជាប្រជាជនទាំងមូលក្នុងលោកនឹងបានទទួលពន្លឺនៃពុទ្ធសាសនាដោយឆាប់រួសរាន់ជាពុំខាន   កាលបើដូច្នោះពៀរទាំងឡាយដែលលែងមាននរណាចងនឹងគ្នាទៀត   នឹងវិនាសសាបសូន្យទៅឯង   ឯពិភពលោកដែលកំពុងឆេះដោយភ្លើងសង្គ្រាមនឹងត្រជាក់គួរជាទីអាស្រ័យនៅទៅឯង   ។

វត្ថុបំណងនឹងកម្មវិធីដែលប្រធានពុទ្ធិកសមាគមពិភពលោកបានថ្លែងក្នុងបាឋកថានេះ   មានអត្ថរសដ៏សំខាន់ប្រពៃណាស់   ប្រសិនបើអាចនឹង

សំរេចបានដូចបំណងមែន មុខជានឹងកើតគុណប្រយោជន៍ទូទៅក្នុងលោកដោយពិត ។

វត្តបំណងដ៏វិសេសខាងនេះ ជាវត្តបំណងនៃសមាគមមិត្តសាលា·បាលីដែរ សមាគមនេះកើតឡើងដើម្បីរួបរួមមិត្តឲ្យមូលសាមគ្គីគ្នា ដើម្បីផ្សាយព្រះពុទ្ធសាសនាឲ្យបានជ្រួតជ្រាបទូទៅក្នុងកម្ពុជរដ្ឋទាំងមូល ដើម្បីកសាងកល្យាណជនឲ្យមានចំនួនកាន់តែច្រើនឡើង ហើយនាំគ្នាថែរក្សានូវមនុស្សធម៌នឹងសីលធម៌ដ៏ពិតប្រាកដឲ្យឋិតថេរក្នុងវង់មនុស្សជាតិ គឺថាបណ្ដុះបណ្ដាលនូវសេចក្ដីសុខ សេចក្ដីចំរើន នឹងសន្តិភាពសំរាប់ជនទូទៅ ។

ព្រោះហេតុនោះ សូមលោកអ្នកទាំងឡាយកុំបំភ្លេចរួបរួមក្នុងកិច្ចដ៏សំខាន់នៃសមាគមមិត្តសាលាបាលី ដោយការប្រមូលគ្នាចុះឈ្មោះជាសមាជិកនឹងជាអ្នកអានទស្សនាវដ្ដីរបស់សមាគម ព្រមទាំងជួយខ្នះខ្នែងក្នុងកិច្ចការសមាគមផង ។

មិត្តសាលាបាលី

# ថ្ងៃផ្សាយមេត្តា

ពុទ្ធិកសមាគមពិភពលោកដែលមានលោកដុកទ័រម៉ាឡាល័ះសេកេរ: ជាប្រធាន បានសុំឲ្យពុទ្ធសាសនិកជនគ្រប់រូបក្នុងលោកនេះ ទោះនៅទីណាកន្លែងណាក៏ដោយ សង្រួមចំនួន ២ នាទីដើម្បីផ្សាយនូវមេត្តាធម៌ក្រាលពេញពិភពលោកទាំងមូល ក្នុងពេលវេលាតែមួយនៃថ្ងៃទី ២១ ឧសភា គ.ស. ១៩៥១ គឺថ្ងៃ ១ កើតខែពិសាខឆ្នាំនេះ ឲ្យបានព្រមព្រៀងគ្នានឹងរួបរួមកម្លាំងមេត្តាចិត្ត ដើម្បីសេចក្ដីសុខ សេចក្ដីចំរើនចំពោះសព្វសត្វទូទៅ ៗ

នៅប្រទេសខ្មែរយើង ពេលម៉ោងដែលកំណត់នោះ គឺម៉ោង ៨ យប់ គ្រប់វត្តអារាមនៅទីក្រុង ពួកពុទ្ធបរិសទ្យបានជួបជុំគ្នានាពេលវេលានោះ មានបណ្ឌិតម៉ាឡាល័ះសេកេរ:រួមជាមួយផង បានចំរើនមេត្តាភាវនា ផ្សាយសេចក្ដីសុខទៅកាន់សព្វសត្វទូទៅក្នុងលោកទាំងមូល:

"សត្វទាំងពួង ដែលមានខ្យល់ចេញចូល កើតហើយរស់ជាមានអត្តភាពពង់កាយ ជាអរិយក្ដី ពុំមែនជាអរិយក្ដី ជាទេវតា មនុស្ស គ្រុឌ នាគ វិទ្យាធរនឹងអសុរកាយក្ដី មានចិត្តក្ដី មិនមានចិត្តក្ដី បណ្ដាមានជីវិតឋិតនៅក្នុងទិសទាំង ៨ ចូរកុំមានពៀរដល់គ្នាឡើយ ចូរកុំព្យាបាទអាឃាតគ្នាឡើយ ចូរកុំមានទុក្ខសោកឡើយ ចូរកុំឲ្យមានរោគ

ភ័យឡើយ ចូរមានអាយុយឺនយូរវែងឆ្ងាយទៅចុះ ចូរសម្រេចនូវសម្បត្តិទាំងពួងចុះ ចូររក្សាខ្លួនឲ្យជាសុខ រួចចាកទុក្ខទាំងពួងចុះ"!

សមាគមមិត្តសាលាបាលីបានរួបរួមក្នុងវិធីនេះ ដោយស្មោះសរ ហើយបានផ្សាយមេត្តាចំពោះអ្នកអានទស្សនាវដ្ដីនេះគ្រប់រូប ព្រមទាំង-សមាជិកគ្រប់គ្នា មួយអន្លើដោយក្រុមគ្រួសារ ហើយបានរាតអំណាចនៃធម៌នោះ ឲ្យសាយទូលាយទៅតាមដែលអាចនឹងផ្សព្វផ្សាយទៅបាន ។ យើងមានសេចក្ដីពេញចិត្តចំពោះកិច្ច ដែលពុទ្ធិកសមាគមពិភពលោកបានផ្ដើមឲ្យធ្វើនេះដ៏ក្រៃពេក ជាកិច្ចពុទ្ធសាសនាពិតប្រាកដ ហើយជាទំនៀមដ៏ល្អមួយសំរាប់អ្នកពុទ្ធមាមកជនក្នុងអនាគតកាល ព្រោះយើងយល់ថា មានតែវិធីមួយនេះទេ ដែលអាចញុំាងសីលធម៌ក្នុងលោកឲ្យចំរើនលូតលាស់ឡើងបាន ជាហេតុនាំឲ្យជីវភាពមានអាការស្រស់ស្រាយរុងរោចន៍បីដូចរាត្រីពេញបូណ៌មី នាំឲ្យយើងរាល់គ្នាបានទទួលនូវសន្តិសុខជាលំដាប់ទៅ ។

គង់មានអ្នកខ្លះយល់ថា គ្រាន់តែតាំងចិត្តផ្សាយមេត្តាប៉ុណ្ណោះកាលណាឡើយនឹងបានសុខមកឯង ៗ កិច្ចធ្វើបែបនោះគ្មានបានផលប្រ-យោជន៍ទេ នរណាមួយមិនចង់បានសុខ ហើយនរណាមួយមិនប្រឹងប្រែងរកសាងសុខសំរាប់ខ្លួនសំរាប់គ្រួសារ ខំខ្នះខ្នែងរាប់ឆ្នាំម្ដេចមិនបាន

សុខ  បំណង់បើគ្រាន់តែភាវនាទទេ ៗ កាលណានឹងបានសុខនោះមកដូចបំណង ៗ

អ្នកដែលពោលបែបនោះជាអ្នកផ្ទៀងទៅខាងរូបនិយម  មិនស្គាល់អំណាចរបស់ចិត្ត  ចិត្តតាមសភាពដើមជាប្រភស្សរចិត្តមានរស្មីភ្លឺថ្លា  មានឫទ្ធិអំណាចអាចធ្វើបាដិហារ្យផ្សេង ៗ បាន  តែបានជាសៅហ្មងមិនមានកំឡាំងខ្លាំងក្លា  ព្រោះមានកិលេសមកចុបគ្របសោបរុំជុំជិត  ការបំរើនភាវនា  គឺការជំរះចិត្តឲ្យស្អាតនោះឯង  គឺការបំរើនកំលាំងដល់ចិត្តឲ្យមានឫទ្ធិតាមប្រក្រតីដើម  លោកបានពោលទុកក្នុងធម្មបទថា:

“ធម៌ទាំងឡាយ  មានចិត្តដល់មុន  មានចិត្តប្រសើរដោយវិសេស  សម្រេចហើយដោយចិត្ត”

សឹងមានឧទាហរណ៍និទស្សនឲ្យឃើញច្បាស់លាស់ក្នុងពុទ្ធប្បវត្តិស្រាប់ ៗ កាលព្រះដ៏មានបុណ្យ  ស្ដេចយាងទៅប្រោសបញ្ចវគ្គិយ  ពួកបញ្ចវគ្គិយនឹកស្មានថាព្រះអង្គពុំទាន់បានត្រាស់ដឹងនៅឡើយ  នាំគ្នាមិនចង់អើពើគោរព  តែចាញ់អំណាចចិត្តព្រះអង្គដែលបានផ្សាយមេត្តាគ្រាលទៅលើក្នុងពេលនោះ  លុះព្រះអង្គចូលទៅជិតពួកបញ្ចវគ្គិយភ្លេចសេចក្ដីមត់គ្នាខាងដើមបង់ ៗ  ដោយអំណាចការផ្សាយមេត្តាធម៌នេះឯងដែលព្រះសម្មាសម្ពុទ្ធអាចផ្ចាញ់ដំរីនាឡាគិរីនឹងអង្គុលិមាលជាដើម ៗ  ការផ្ចាញ់អង្គុលិមាលគួរឲ្យអស្ចារ្យក្រៃពេក  ព្រោះអង្គុលិមាលជាចោរ

សាហាវយង់ឃ្នង សំឡាប់មនុស្សគាត់យកម្រាមដៃចំនួន ៩៩៩ នាក់មក ហើយ នៅតែម្នាក់ទៀតទើបគ្រប់ ១០០០ ដេញតាមសំឡាប់ព្រះដ៏មានព្រះភាគដែលទ្រង់យាងដោយស្រួល ដល់ហបមាត់នៅតែមិនទាន់ ចំស្រែកឲ្យព្រះអង្គឈប់ ព្រះអង្គឆ្លើយប្រាប់ថាឈប់ហើយតែអង្គុលិមាល នៅតែរត់តាមពុំទាន់ ទឹកខឹងស្ដីបន្ទោសព្រះអង្គថា ធ្វើជាសមណៈដូចម្ដេចក៏ពោលពាក្យមិនពិត ឆ្លើយថាឈប់ហើយនៅតែដើរ ទើបព្រះអង្គតបទៅវិញថា តថាគតឈប់ហើយ នៅតែអ្នកឯងទេដែលពុំទាន់ឈប់ គឺឈប់កាន់ដំបងព្រនង់ ដោយអំណាចមេត្តាធម៌របស់ព្រះអង្គ អង្គុលិ-មាលទន់ដៃទន់ជើងទំលាក់ដំបងព្រនង់សុំបព្វជ្ជាក្នុងព្រះពុទ្ធសាសនា ។

រឿងក៏ដែលមានដំណាលក្នុងពុទ្ធប្បវត្តិជាសំអាងឲ្យឃើញនូវកំឡាំងមេត្តាធម៌ដោយច្បាស់លាស់ ចំណែកកម្លាំងឬអានុភាពរបស់ចិត្ត យើងអាចដឹងបានស្រាប់ហើយ សូម្បីរាងកាយកំពុងអស់កំឡាំងកំរើកពុំរួចដូចម្ដេចក្ដី ចិត្តអាចបង្គាប់រាងកាយកំសោយនោះឲ្យរត់ឲ្យដើរឬឲ្យធ្វើអ្វី ៗ បានក្នុងកាលខ្លះ ៗ ដូចកាលយើងចូលទៅរកអ្នកខ្លះ ដែលមានកម្លាំងចិត្តខែងរ៉ែង គេមិនធ្វើអ្វីយើងទេ តែយើងនៅខ្លាច អស់ទុកចិត្តខ្លួនឯងចំពោះមុខអ្នកនោះ ឯគ្រាប់បែកបរមាណូដែលផ្ទុះឡើងសំឡាប់មនុស្សរាប់សែននាក់ក៏ជាផលនៃចិន្តាមួយប៉ុណ្ណោះ ដោយហេតុនោះទើបលោកពោលក្នុង

ធម្មបទថា លោកនេះគ្រប់គ្រងដោយចិត្ត ។ តែក្នុងទីនេះ យើងពោលតែពីមេត្តាធម៌ប៉ុណ្ណោះ ។

មេត្តាគឺអ្វី? មេត្តាគឺកំណើតនៃធម៌ដែលញ៉ាំងចិត្តឲ្យទោរទន់ទៅកាន់សព្វសត្វទាំងឡាយដោយសេចក្ដីស្រឡាញ់ស្មោះស្ម័គ្រ ដោយប៉ុនប៉ងចង់ឲ្យបានប្រកបដោយសេចក្ដីសុខសេចក្ដីចំរើន ទោះជាអ្នកដទៃក្ដីទោះជាសត្រូវក្ដី ទោះនៅទីណាកន្លែងណាឋានៈយ៉ាងណាក្ដី តាំងចិត្តស្នេហាបីដូចមាតាគ្រងរក្សាបុត្រតែមួយដោយមិនខ្លាចគ្រោះថ្នាក់ដល់ជីវិត ជាសេចក្ដីស្នេហាដ៏ខ្ពង់ខ្ពស់ដោយគ្មានត្រូវការប្រាថ្នាអ្វីតបវិញ ដោយគ្មានចង់បានអ្វីមកជារបស់ខ្លួន គឺស្នេហាដើម្បីស្នេហា ដើម្បីញ៉ាំងចិត្តអាត្មាឲ្យអស់ក្ដីឃោរឃៅឲ្យត្រជាក់មិនឲ្យក្ដើងកិលេសដុតរោលរាលបាន ជាសេចក្ដីស្នេហាដោយយល់ច្បាស់ថាជនដទៃស្អប់ទុក្ខ ស្រឡាញ់សុខដូចខ្លួនដែរ ដោយត្រៀមខ្លួនទឹងជួយបណ្ដាលសុខនោះឲ្យកើតឡើងបំបាត់ទុក្ខនោះឲ្យអស់ទៅ ជាសេចក្ដីស្នេហាដែលប្រគល់វិមុត្តិដល់ចិត្ត ។

មេត្តាធម៌នេះឯងជាគុណធម៌យោងមនុស្សឲ្យតាំងខ្លួនជាមនុស្សពេញលេញ ឲ្យឃ្លាតចាកសន្ដានតិរច្ឆាន ដែលមាននិស្ស័យតែងប្រទុសរ៉ាយគ្នាជាធម្មតា កាលកំលាំងមនុស្សធម៌នេះទន់ខ្សោយហើយ យើងនឹងវិលទៅកាន់អនារ្យភាពដោយពិត ។ មេត្តាធម៌ជាអាវុធដ៏សំខាន់មួយសំរាប់កាប់ផ្ដាច់នូវអត្តទត្តភាព ដែលជារបងបាំងមនុស្សជាតិដូចគ្នា មិនឲ្យ

មូលមិត្តរាប់រកគ្នាបាន សំរាប់ផ្ដាញ់ផ្ដាលនូវកិលេសជាសត្រូវដោយច្រើន មានលោភៈជាអាទិ ដែលជាមូលហេតុញុំាងសេចក្ដីព្យាបាទចងពៀរគ្នា ។ អ្នកគ្មានពៀរ គ្មានសេចក្ដីរង្កៀសចំពោះជនដទៃ គ្មានរង្កៀសក្នុងខ្លួនដោយកិលេសបៀតបៀន ឈ្មោះថាបានសេចក្ដីស្ងប់ កាលបានសេចក្ដីស្ងប់ហើយ ឈ្មោះថាបានសេចក្ដីសុខ ។ អ្នកមានមេត្តាធម៌រមែងដេកលក់នៅជាសុខភ្ញាក់ឡើងក៏ជាសុខ ឯភ្លើងក្ដី ពិសក្ដី គ្រឿងសាស្ត្រាវុធក្ដី រមែងមិនឆេះ មិនពុល មិនមុតចំពោះបុគ្គលអ្នកមានមេត្តាធម៌នោះ ។

ដូច្នេះ មេត្តាធម៌ជាកំលាំងដ៏ប្រសើរមួយ ដែលផ្សាយនូវកំលាំងមិត្ត-ភាពទូទៅ បំបាត់នូវពៀរទាំងឡាយ ដែលប្រកាសចេញទៅដោយការឈ្លោះប្រកែក ដណ្ដើមឈ្នះចាញ់ កាប់សំឡាប់គ្នាជាដើម គឺជាមូលដ្ឋាននៃសេចក្ដីសុខ រវាងមនុស្សនឹងមនុស្ស រវាងមនុស្សនឹងខ្លួនមនុស្សនោះ ការផ្សាយនូវមេត្តាធម៌ឈ្មោះថាកសាងនូវសុខដោយពិតប្រាកដ មេត្តាធម៌នេះឯងជាឫសកែវនៃការបំពេញសីលនឹងការធ្វើទានឈ្មោះថាគុណធម៌ដ៏ឧត្តមសំរាប់លើកដំកើងនូវសីលធម៌នឹងមនុស្សធម៌ឲ្យប្រាកដក្នុងលោក ។

សត្វទាំងឡាយ ដែលកំពុងមានទុក្ខ សូមឲ្យអស់ទុក្ខទៅ !
សត្វទាំងឡាយដែលកំពុងមានភ័យ សូមឲ្យអស់ភ័យទៅ!
សត្វទាំងឡាយដែលកំពុងសោក សូមឲ្យអស់សោកទៅ !

មិត្តសាលាបាលី